ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅ
# គោលការណ៍ណែនាំបន្ថែមសម្រាប់
# ការវាយតម្លៃស្តង់ដាសហគមន៍ទេសចរណ៍ និងផ្ទះស្នាក់កម្ពុជា





## ២០២២

រៀបចំដោយៈ ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍
និងលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

# មាតិកា


**ជំពូកទី១៖ សេចក្តីផ្តើម......................................................................................៩**

១. បរិបទនៃការវិវត្តន៍សហគមន៍ទេសចរណ៍......................................................១០

២. គោលបំណងនៃការរៀបចំចងក្រងសៀវភៅ......................................................១២

៣. បញ្ហាប្រឈមក្នុងសហគមន៍ទេសចរណ៍..........................................................១២

៤. ការអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍......................................១៣

**ជំពូកទី២៖ ខ្លឹមសារនៃគោលការណ៍ណែនាំសម្រាប់.............................................១៤**

**ក. សហគមន៍ទេសចរណ៍.............................................................................១៥**

**ផ្នែកទី១៖ ខ្លឹមសារសហគមន៍ទេសចរណ៍.......................................................១៦**

១. សូចនាករគោល នៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រង...................................១៧

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល...................................................... ១៧

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..............................................................១៨

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................... ២០

២. សូចនាករគោល នៃការរួមចំណែកដល់សុខុមាលភាពសង្គម................................២១

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.......................................................២១

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..............................................................២២

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..........................................................................២៧

៣. សូចនាករគោល នៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ............................២៨

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.......................................................២៨

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..............................................................៣០

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..........................................................................៣២

៤. សូចនាករគោល នៃការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងទេសចរ.......៣៣

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.......................................................៣៣

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..............................................................៣៥

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................៣៦

៥. សូចនាករគោលទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៏..................................៣៨

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.............................................................៣៨

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល.................................................................៤០

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................៤២

៦. សូចនាករគោលគុណភាពម្ហូបអាហារ និងភេសជ្ជៈ.................................................៤៤

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.............................................................៤៤

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល.................................................................៤៥

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................៤៨

៧. សូចនាករគោលគុណភាពស្នាក់នៅ.......................................................................៤៩

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.............................................................៤៩

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល.................................................................៥០

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................៤២

៨. សូចនាករគោលការអនុវត្តនៃប្រតិបត្តិករទេសចរណ៍សហគមន៍......................................៥៤

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល.............................................................៥៤

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល.................................................................៥៥

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................៥៧

**ផ្នែកទី២៖ យន្តការនៃការផ្តល់ពិន្ទុជូនសហគមន៍ទេសចរណ៍**.......................**៥៨**

សេចក្តីពន្យល់បន្ថែមទី១..................................................................................៥៩

សេចក្តីពន្យល់បន្ថែមទី២..................................................................................៦០

**ផ្នែកទី៣៖ ដំណើរការនៃការវាយតម្លៃសហគមន៍ទេសចរណ៍**......................**៦១**

**ផ្នែកទី៤៖ ដំណើរការនៃការប្រឡងប្រណាំងសហគមន៍ទេសចរណ៍**..........**៦២**

**ឧបសម្ព័ន្ធ**..................................................................................................**៦៣**

**២. ផ្ទះស្នាក់សហគមន៍...................................................................................៦៤**

**ផ្នែកទី១៖ ខ្លឹមសារផ្ទះស្នាក់...................................................................................៦៥**

**ក. ផ្ទះស្នាក់សហគមន៍.......................................................................................៦៦**

១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់សហគមន៍......................................................................៦៧

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល......................................................................៦៧

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៦៨

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................................៧០

២. សូចនាករគោលនៃកន្លែងស្នាក់នៅ................................................................................៧២

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល......................................................................៧២

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៧២

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................................៧៤

៣. សូចនាករគោលនៃទីតាំងស្នាក់នៅ................................................................................៧៥

ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៧៥

ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................................៧៦

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត.....................................................................៧៧

ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៧៧

ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................................៧៨

៥. សូចនាករគោលនៃសកម្មភាពកំសាន្ត............................................................................៧៩

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល......................................................................៧៩

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៨០

គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.......................................................................................៨១

៦. សូចនាករគោលនៃសុខសុវត្ថិភាព.................................................................................៨៣

ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល......................................................................៨៣

ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៨៣
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................៨៥

៧. សូចនាករគោលនៃការគ្រប់គ្រង.....................................................................................៨៧
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល........................................................................៨៧
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៨៨
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................៨៩

៨. សូចនាករគោលនៃការសិក្សាទីផ្សារ និងផ្សព្វផ្សាយ...............................................................៩០
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល........................................................................៩០
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៩០
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................៩២

៩. សូចនាករគោលនៃគោលការណ៍និរន្តភាព..........................................................................៩៣
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល........................................................................៩៣
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៩៤
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................៩៦

**ខ. ផ្ទះស្នាក់ជនបទ.....................................................................................៩៨**

១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ជនបទ..........................................................................៩៩
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល........................................................................៩៩
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................៩៩
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................១០២

២. សូចនាករគោលនៃកន្លែងស្នាក់នៅ..............................................................................១០៣
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល........................................................................១០៣
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១០៣
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ.....................................................................................១០៥

៣. សូចនាករគោលនៃទីតាំងស្នាក់នៅ..............................................................................១០៦

ក. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១០៦
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១០៧

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត..........................................................១០៨
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១០៨
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១០៩

៥. សូចនាករគោលនៃសកម្មភាពកំសាន្ត..............................................................១១០
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១១០
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១១១

៦. សូចនាករគោលនៃសុខសុវត្ថិភាព....................................................................១១៣
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១១៣
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១១៥

៧. សូចនាករគោលនៃការផ្សព្វផ្សាយ....................................................................១១៦
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១១៦
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១១៧

៨. សូចនាករគោលនៃគោលការណ៍និរន្តភាព..........................................................១១៨
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១១៨
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១២០

**គ. ផ្ទះស្នាក់ទីក្រុង..........................................................................................១២២**
១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ជនបទ..........................................................១២៣
ក. និយមន័យនៃពាក្យគន្លឹះសូចនាករគោល..........................................................១២៣
ខ. លក្ខណ្ឌតម្រូវរបស់សូចនាករគោល................................................................១២៣
គ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ......................................................................១២៦

២. សូចនាករគោលនៃកន្លែងស្នាក់នៅ..................................................................១២៧

ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១២៧
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១២៨

៣. សូចនាករគោលនៃទីតាំងស្នាក់នៅ................................................................................១៣០
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១៣០
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១៣១

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត..........................................................................១៣២
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១៣២
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១៣៣

៥. សូចនាករគោលនៃសកម្មភាពកំសាន្ត.............................................................................១៣៤
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១៣៤
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១៣៦

៦. សូចនាករគោលនៃសុខសុវត្ថិភាព.................................................................................១៣៧
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១៣៧
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១៣៨

៧. សូចនាករគោលនៃការផ្សព្វផ្សាយ.................................................................................១៣៩
ក. លក្ខណ្ឌតម្រូវរបស់សូចនាករគោល..........................................................................១៣៩
ខ. និតិវិធីក្នុងការផ្តល់ជូនពិន្ទុ..............................................................................................១៤១

**ផ្នែកទី២៖ យន្តការនៃការផ្តល់ពិន្ទុជូនផ្ទះស្នាក់កម្ពុជា**..........................................................**១៤៣**

**ផ្នែកទី៣៖ ដំណើរការនៃការវាយតម្លៃផ្ទះស្នាក់កម្ពុជា**..........................................................**១៤៤**

**ផ្នែកទី៤៖ ដំណើរការនៃការប្រឡងប្រណាំងផ្ទះស្នាក់គម្រូ**......................................................**១៤៥**

**ឧបសម្ព័ន្ធ**..................................................................................................................**១៤៦**

# ក្រុមការងាររៀបចំចងក្រងឯកសារ

១. **ឯកឧត្តមបណ្ឌិត ជុក ជំនោរ** ប្រធាននាយកដ្ឋានអភិវឌ្ឍផលិតផលទេសចរណ៍ និងជាប្រធានលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចណ៍ និងអេកូទេសចរណ៍

២. លោក **ចាន់ ខេមរិទ្ធ** អនុប្រធានផ្នែកគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍

៣. កញ្ញា **ហ៊ួន លីណា** មន្ត្រីនាយកដ្ឋានអភិវឌ្ឍផលិតផលទេសចរណ៍

៤. កញ្ញា **ស៊ឹង ស្រីលក្ខណ៍** មន្ត្រីនាយកដ្ឋានអភិវឌ្ឍផលិតផលទេសចរណ៍

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១. បរិបទនៃការវិវត្តន៍សហគមន៍ទេសចរណ៍

វិស័យទេសចរណ៍ បានក្លាយជាសសរស្តម្ភមួយនៃខឿនសេដ្ឋកិច្ចកម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកជា "**មាសបៃតង**"។ ជាក់ស្តែង ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ វិស័យទេសចរណ៍កម្ពុជាបានរីកលូតលាស់គួរឲ្យកត់សម្គាល់ ហើយបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍជាតិ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៩ ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិ មានចំនួនស្មើនឹង **៦,៦ លាននាក់** កើនឡើង **៣ដង** ប្រៀបធៀបនឹង ១០ឆ្នាំមុន ដែលមានចំនួនត្រឹមតែ **២,១៦ លាននាក់**ប៉ុណ្ណោះ។ ការកើនឡើងគួរឲ្យកត់សម្គាល់នេះ អាចធ្វើទៅបានដោយផ្អែកទៅលើសុខសន្តិភាពទូទាំងប្រទេសក្នុងអំឡុងពេលជា ២ ទសវត្សរ៍មកនេះ។ សន្តិភាពនេះ បានអនុញ្ញាតឲ្យមានការអភិវឌ្ឍ និងការរៀបចំរមណីយដ្ឋានច្រើនប្រភេទ ច្រើនកន្លែង គ្រប់ទិស និងគ្រប់តំបន់ ដោយមិនពឹងផ្អែកតែលើរមណីយដ្ឋានប្រវត្តិសាស្ត្រនៃតំបន់អង្គរវត្តប៉ុណ្ណោះទេ។ ជាមួយគ្នានេះ ចំណូលដុលពីទេសចរណ៍អន្តរជាតិ ក្នុងឆ្នាំ២០១៩ មានទំហំស្មើនឹង **៤៩១៩ លានដុល្លារអាមេរិក** ឬស្មើនឹងជិត **១៣% នៃផសស** របស់ប្រទេសកម្ពុជា។ បើគិតជាតម្លៃបន្ថែមវិញ វិស័យទេសចរណ៍ចូលរួមចំណែកប្រមាណ **៤.៤% នៃផសស** កម្ពុជា ក្នុងឆ្នាំ២០១៩ និងជាអនុវិស័យធំជាងគេទី៤ នៅក្នុងវិស័យសេវាកម្ម បន្ទាប់ពីអនុវិស័យពាណិជ្ជកម្ម ដឹកជញ្ជូន និងទូរគមនាគមន៍ និងអចលនទ្រព្យ។ វិស័យទេសចរណ៍ក៏បានបង្កើតមុខរបរ និងការងារទេសចរណ៍ដោយផ្ទាល់ប្រមាណជាង **៦៣ ម៉ឺននាក់** និងការងារដោយប្រយោលរាប់សិបម៉ឺននាក់បន្ថែមទៀត។ ជាមួយគ្នានឹងកំណើននេះ មានការកើនឡើងនៃនិន្នាការទេសចរណ៍នៅតាមសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ផងដែរ។

ខណៈដែលវិស័យទេសចរណ៍ពិភពលោក មានកំណើនក្នុងរង្វង់ប្រមាណ **៥%** ក្នុងមួយឆ្នាំ វិស័យអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍មានកំណើនប្រមាណ **២០%** ជារៀងរាល់ឆ្នាំ។ ទេសចរណ៍សហគមន៍ និងអេកូទេសចរណ៍ ត្រូវបានចាត់ទុកថាជាសសរស្តម្ភក្នុងការធានាការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ដូចដែលត្រូវបានគូសបញ្ជាក់ដោយ រដ្ឋមន្ត្រីទេសចរណ៍ពិភពលោក នាឱកាសវេទិកាតុមូល ក្រោមប្រធានបទ **"វប្បធម៌ និងប្រជាពលរដ្ឋ"** ដែលត្រូវបានរៀបចំឡើងដោយអង្គការទេសចរណ៍ពិភពលោក នៅទីក្រុងអូសាកា ប្រទេសជប៉ុន។

ដោយឡែក ក្នុងក្របខណ្ឌនៃរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន កម្ពុជាគឺជាប្រទេសនាំមុខក្នុងការរៀបចំ**ស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន (អនុម័តឆ្នាំ២០១៦)** និង**ស្តង់ដាផ្ទះស្នាក់អាស៊ាន (អនុម័តឆ្នាំ២០១៤)** ហើយកាលពីវេទិកាទេសចរណ៍អាស៊ានកាលពីខែមករា ឆ្នាំ២០១៩ រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន បានផ្តល់រង្វាន់សហ

គមន៍ទេសចរណ៍អាស៊ាន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ចំនួន **២៦** ក្នុងនោះសហគមន៍ទេសចរណ៍កម្ពុជាចំនួន ០៣ គឺ**សហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង** ក្នុងខេត្តកោះកុង **សហគមន៍ទេសចរណ៍កំពង់ភ្លុក** ក្នុងខេត្តសៀមរាប និង**សហគមន៍ទេសចរណ៍បន្ទាយឆ្មារ** ក្នុងខេត្តបន្ទាយមានជ័យ។

បច្ចុប្បន្នមានសហគមន៍ប្រមាណជាង **២៣០០ កន្លែង** ដែលត្រូវបានបង្កើតឡើង និងគ្រប់គ្រងដោយក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងនោះ មានតែសហគមន៍ប្រមាណ **១២៣ កន្លែង** ប៉ុណ្ណោះ ដែលមានបញ្ចូលសកម្មភាពទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងនោះរួមមាន៖

- **ក្រសួងទេសចរណ៍**៖ ចំនួន **៧៩ សហគមន៍**
- **ក្រសួងបរិស្ថាន**៖ ចំនួន ***១៦៨ សហគមន៍តំបន់ការពារធម្មជាតិ*** ក្នុងនោះ **២០** សហគមន៍មានសកម្មភាពទេសចរណ៍
- **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**៖
  - សហគមន៍នេសាទ ចំនួន **៥១៦** ក្នុងនោះ **២៤** មានសកម្មភាពអេកូទេសចរណ៍ និងចំនួន **១២៦** មានសក្តានុពលរៀបចំជាសហគមន៍អេកូទេសចរណ៍
  - សហគមន៍កសិកម្ម ចំនួន **១១១៦** និងកំពុងសិក្សាសហគមន៍ដែលមានសក្តានុពលក្នុងការបញ្ចូលសកម្មភាពទេសចរណ៍
  - សហគមន៍ព្រៃឈើ ចំនួន **៤៨៤ *សហគមន៍*** និងកំពុងសិក្សាសហគមន៍ដែលមានសក្តានុពលក្នុងការបញ្ចូលសកម្មភាពទេសចរណ៍

ជារួម ដោយមើលឃើញពីសក្តានុពលទេសចរណ៍សហគមន៍ និងអេកូទេសចរណ៍កំពុងមាននិន្នាការកើនឡើងជាបន្តបន្ទាប់។ ដូច្នេះ ចាំបាច់តម្រូវឱ្យមានការរៀបចំជាសៀវភៅគោលការណ៍ណែនាំសម្រាប់ "**សហគមន៍ទេសចរណ៍ និងផ្ទះស្នាក់កម្ពុជា**" នេះឡើង។

## ២. គោលបំណង

១. ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ជនបង្គោលវាយតម្លៃថ្នាក់ជាតិ និងក្រោមជាតិ

២. ផ្តល់ភាពងាយស្រួលដល់ជនបង្គោលក្នុងការចុះវាយតម្លៃស្តង់ដា

៣. មានភាពងាយស្រួលតាមដាន និងត្រួតពិនិត្យជនបង្គោលថ្នាក់ជាតិ និងក្រោមជាតិ

## ៣. បញ្ហាប្រឈមក្នុងសហគមន៍ទេសចរណ៍

-**ទី១៖ សមត្ថកិច្ចក្នុងការគ្រប់គ្រងមានភាពមិនច្បាស់លាស់** ដោយសហគមន៍មួយចំនួនមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ប៉ុន្តែបានចុះបញ្ជីត្រឹមតែឃុំ ស្រុក ដែលដែនសមត្ថកិច្ចស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខេត្ត។ សហគមន៍មួយចំនួនទៀតបានចុះបញ្ជីទៅក្រសួងមហាផ្ទៃ ប៉ុន្តែដែនសមត្ថកិច្ចនៃគ្រប់គ្រង នៅតែមិនច្បាស់លាស់ និងចម្រូងចម្រាស់ ដែលជាហេតុធ្វើឲ្យមន្ទីរទេសចរណ៍ជំនាញថ្នាក់ក្រោមជាតិពិបាកលូកដៃដំណើរការនៃការគ្រប់គ្រងសហគមន៍នោះ។

-**ទី២៖** ការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ ជាពិសេសរវាងសហគមន៍ មន្ទីរបរិស្ថាន និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត នៅមិនទាន់មានភាពរលូនពេញលេញក្នុងតំបន់មួយចំនួន ជាពិសេសករណីរបស់សហគមន៍បឹងពារាំង សង្កាត់ជ្រាវ ក្នុងខេត្តសៀមរាប។

-**ទី៣៖** ការបញ្ចូលសកម្មភាពទេសចរណ៍ និងការប្រើប្រាស់ឈ្មោះជាសហគមន៍ទេសចរណ៍ហាក់មិនទាន់ត្រូវបានលើកទឹកចិត្តពេញលេញពីសំណាក់ភាគីពាក់ព័ន្ធ។ ក្នុងន័យនេះ ក្រសួងទេសចរណ៍ រក្សាជំហរក្នុងការជួយគ្រប់សហគមន៍ទេសចរណ៍ទាំងអស់ ទាំងសហគមន៍ទេសចរណ៍ដែលនៅក្រោមក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង-ស្ថាប័នផ្សេងៗ ក្នុងការជំរុញសកម្មភាពទេសចរណ៍ក្នុងសហគមន៍ ចាប់ពីដំណាក់កាលនៃការបង្កើតរហូតដល់មានការអភិវឌ្ឍ។ ត្រង់ចំណុចនេះ **ក្រសួងទេសចរណ៍ មិនដែលទាមទារការគ្រប់គ្រងសហគមន៍ដែលស្ថិតនៅក្រោមក្រសួងផ្សេងទេ គឺមានតែការជំរុញសកម្មភាពទេសចរណ៍ក្នុងសហគមន៍ទាំងនោះ។**

## ៤. ការអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

- រាជរដ្ឋាភិបាលបានបង្កើត**ក្រុមការងារអន្តរក្រសួងបានជំរុញការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍** តាមរយៈសេចក្តីសម្រេចលេខ ១០០ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ដែលមាន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថានជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាអនុប្រធាន និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈអភិបាលរាជធានី-ខេត្តជាសមាជិក។

- រាជរដ្ឋាភិបាលអនុម័ត**គោលនយោបាយជាតិអេកូទេសចរណ៍ (២០១៩-២០៣០)** កាលពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី។**

- ក្រសួងទេសចរណ៍បានរៀបចំចងក្រងសៀវភៅស្តង់ដាសហគមន៍ទេសចរណ៍កម្ពុជា និងផ្ទះស្នាក់កម្ពុជា និងបានដាក់ប្រកាសឱ្យអនុវត្តជាផ្លូវការនាថ្ងៃទី១២ ខែកញ្ញា ឆ្នាម២០១៦ សំដៅដល់ការពង្រឹងគុណភាព សេវាកម្មទេសចរណ៍ក្នុងសហគមន៍ប្រកបដោយចីរភាព គុណភាព ប្រសិទ្ធិភាព និងការទទួលខុសត្រូវ។

# ជំពូកទី២
# ខ្លឹមសារគោល
# ការណែនាំ

# ក. សហគមន៍ទេសចរណ៍

# ផ្នែកទី១៖ សហគមន៍ទេសចរណ៍

ទេសចរណ៍សហគមន៍ ត្រូវបានចាត់ទុកថាជាឧបករណ៍មួយយ៉ាងសំខាន់បានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ជាពិសេសសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន តាមរយៈសកម្មភាព សេវាកម្មទេសចរណ៍ដែលបង្ហាញពីទំនៀមទំលាប់ប្រពៃណី និងរបៀបរបបរស់នៅ ការអភិរក្សវប្បធម៌ និងធនធានធម្មជាតិ ការធ្វើពិពិធកម្មផលិតផលសិប្បកម្ម និងវត្ថុអនុស្សាវរីយ៍ ជំរុញការរៀបចំជាកញ្ចប់ខ្សែទស្សនកិច្ច។ ទាំងអស់នេះបានចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ ដោយបង្កើតឱ្យមានប្រាក់ចំណូលដោយផ្ទាល់ បង្កើតមុខរបរការគាំទ្រ និងអភិរក្សវប្បធម៌ សិល្បៈប្រពៃណី។ល។ ការរៀបចំស្តង់ដាសហគមន៍ទេសចរណ៍ មានលក្ខណៈជាប្រព័ន្ធដោយទាមទារឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ ផ្នែកសាធារណៈ ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាលដែលមានការពាក់ព័ន្ធវិស័យទេសចរណ៍ និងប្រជាពលរដ្ឋសហគមន៍មូលដ្ឋាន។ ដោយក្នុងនោះ ស្តង់ដាសហគមន៍ទេសចរណ៍មានសូចនាករគោលចំនួន**០៨ មានសូចនាករលំអិតចំនួន២៣** និងមាន**លក្ខណៈវិនិច្ឆ័យសរុបចំនួន១៦៩**។ ទន្ទឹមនេះ មាន**៨៦លក្ខណៈវិនិច្ឆ័យ "កម្រិតមធ្យម" ៥២លក្ខណៈវិនិច្ឆ័យ "កម្រិតខ្ពស់"** និង **៣១លក្ខណៈវិនិច្ឆ័យ "កម្រិតខ្ពស់បំផុត"**។

ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ និងអនុវត្តគោលការណ៍ណែនាំនេះ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារបានរៀបចំបែងចែកជា ០៤ចំនុចបន្ថែមទៀតដែលរួមមានដូចខាងក្រោម៖

- និយមន័យនៃពាក្យគន្លឹះក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- លក្ខខណ្ឌតម្រូវនៅក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- និតិវិធីក្នុងការផ្តល់ពិន្ទុសម្រាប់ការវាយតម្លៃ
- រូបភាពបញ្ជាក់បន្ថែម (ក្នុងករណីចាំបាច់) ដើម្បីមានភាពងាយស្រួលយល់កាន់តែច្បាស់

# ១ សូចនាករគោលនៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍

## កម្មវត្ថុនៃសូចនាករនៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍

ទេសចរណ៍សហគមន៍ ជាផ្នែកមួយនៃទេសចរណ៍គឺជាទីផ្សារថ្មីមួយដែលងើបឡើង ស្របនឹងនិន្នាការអេកូទេសចរណ៍ នៅលើពិភពលោកទាំងមូលដែរ។ ការគ្រប់គ្រងសហគមន៍ទេសចរណ៍ ជាយន្តការមួយដ៏សមស្របសម្រាប់ការអភិវឌ្ឍក្នុងតំបន់ធម្មជាតិមួយ ដែលមានប្រជាពលរដ្ឋមូលដ្ឋានរស់នៅផ្សារភ្ជាប់ទៅនឹងធនធានធម្មជាតិក្នុងកម្រិតអតិបរមាដែលការអភិវឌ្ឍនេះនឹងធ្វើឱ្យគ្រប់ភាគីពាក់ព័ន្ធ ពិសេសប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមយ៉ាងសកម្មតាមរយៈការផ្ដល់សិទ្ធិអំណាចក្នុងការសម្រេចចិត្ត ការទទួលផលដោយផ្ទាល់ពីទេសចរណ៍ប្រកបដោយសមធម៌ បង្កើននូវកម្រិតជីវភាពចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយចំណាកស្រុករបស់ប្រជាជនមូលដ្ឋានប្រកបដោយប្រសិទ្ធិភាព ហើយផលប្រយោជន៍ដែលបានមកពីធនធានធម្មជាតិ តាមរយៈវិស័យទេសចរណ៍នឹងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានចូលរួមការពារ អភិរក្សធនធានធម្មជាតិ និងបរិស្ថានជុំវិញខ្លួន។

### ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | អភិបាលកិច្ច | សំដៅដល់វិធីសាស្ត្រក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គម និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍រួមអតិបរមាជូនប្រជាពលរដ្ឋ។ |
| ២ | តម្លាភាព | សំដៅដល់ការចាត់ចែង និងគ្រប់គ្រងកិច្ចការនានា រាប់បញ្ចូលទាំងកិច្ចការហិរញ្ញវត្ថុដោយអនុលោមតាមបទដ្ឋាននៃតម្លាភាព។ |
| ៣ | ប្រសិទ្ធិភាព | សំដៅដល់ការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ និងបរិមាណច្រើន។ |
| ៤ | ប្រតិបត្តិករ | សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍។ |
| ៥ | ការីទេសចរណ៍ | សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្ដុំសេវាកម្មទេសចរណ៍ ផ្សេងៗទៀតសម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា។ |

## ការពន្យល់បន្ថែមលម្អិតនៃពាក្យ "អភិបាលកិច្ច"

ដើម្បីឈានទៅសម្រេចបាននូវអភិបាលកិច្ចល្អបាន ចាំបាច់ត្រូវមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព។ ចំណុចសំខាន់ៗនៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាពរួមមាន៖

- ត្រូវមានសេវាថែទាំសុខភាពល្អប្រសើរ និងគ្រប់គ្រាន់សម្រាប់ប្រជាជនទូទៅ
- ត្រូវមានសេវាអប់រំល្អប្រសើរ និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ
- ត្រូវបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បទទួលបាននូវផលប្រយោជន៍ផ្សេងៗ

### <u>គោលការណ៍នៃអភិបាលកិច្ចល្អ</u>




## ការពន្យល់បន្ថែមលម្អិតនៃពាក្យ "តម្លាភាព"

- ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានា
- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តត្រូវផ្សព្វផ្សាយជាចំហ
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយស្រួលយល់

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍ មានសូចនាករលំអិតចំនួន០៤ ដែលរួមមានដូចខាងក្រោមនេះ៖




លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ “**ប្រសិទ្ធិភាព និងតម្លាភាពនៅក្នុងសហគមន៍**” ដែលនេះ ទាមទារឱ្យមានយន្តការគ្រប់គ្រងច្បាស់លាស់មួយ ដើម្បីដឹកនាំសហគមន៍ឆ្ពោះទៅរកភាពជោគជ័យបាន។ ដូចនេះ លក្ខខណ្ឌត្រូវសម្រាប់សូចនាករគោលនេះ រួមមានដូចខាងក្រោម៖

- បង្ហាញពីវត្តមាននៃការជ្រើសរើសប្រធានសហគមន៍ និងសមាជិកសហគមន៍
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ

ខាងក្រោមនេះ ជាតារាងបង្ហាញពីចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង០៣ខាងលើនេះ

| **តារាងបំពេញលក្ខណ្ឌតម្រូវ នៃសូចនាករគោលនៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍** | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃការជ្រើស | រៀបចំចងក្រងជាយន្តការ វិធាន | • មានសេចក្តីសម្រេច ឬលិខិត |

| | | | |
|---|---|---|---|
| | រើសប្រធានសហគមន៍ និងសមាជិកសហគមន៍ | ការ ឬនីតិវិធីផ្សេងៗ សម្រាប់ធ្វើការកំណត់ក្នុងការជ្រើសរើសប្រធាន និងសមាជិកសហគមន៍ | បទដ្ឋាននានា<br>• មានសេចក្តីប្រកាសជាផ្លូវការ |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវ | រៀបចំ និងចាត់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែង | បែងចែកក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃលើការងារទាំងអស់នេះ | • មានបញ្ជីឈ្មោះរាយនាម[1] ក្រុមការងារទទួលបន្ទុក ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលនៃកម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍ សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **"កម្រិតមធ្យម"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់បំផុត"** |
|---|---|---|---|---|---|
| ១.កម្មសិទ្ធិសហគមន៍ និងការគ្រប់គ្រងសហគមន៍ | **៤** | **១៨** | **១០** | **៦** | **២** |

សម្រាប់និតិវិធីក្នុងការផ្តល់ពិន្ទុវាយតម្លៃសហគមន៍ទេសចរណ៍ ត្រូវបានចែកចេញជា០២ចំនុចរួមមាន៖

[1] តារាងទី០១



១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា *(**តារាង**ភស្តុតាងបញ្ជាក់)*

⚠ **<u>សំគាល់៖</u>** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានាផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

## ២ សូចនាករគោលនៃការរួមចំណែកដល់សុខុមាលភាពសង្គម

### កម្មវត្ថុនៃសូចនាករការរួមចំណែកដល់សុខុមាលភាពសង្គម

ការយកចិត្តទុកដាក់របស់អាជ្ញាធរមូលដ្ឋានក្នុងការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពសហគមន៍ និងសង្គម ដោយធានាជូនប្រជាជនទទួលបានធនធានមូលដ្ឋានដូចជា លំនៅដ្ឋាន ការថែទាំសុខភាព ការអប់រំ និងឱកាសការងារផងដែរ ព្រមជាមួយនឹងការចូលរួមដល់កិច្ចការថែរក្សា និងអភិវឌ្ឍទំនៀមទំលាប់ប្រពៃណី និងបេតិកភណ្ឌវប្បធម៌ផងដែរ។

### ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្ដីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | សុខុមាលភាពសង្គម | សំដៅដល់ប្រព័ន្ធសង្គមមួយដែលមានការទទួលខុសត្រូវចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋតាមរយៈការទទួលបានការថែទាំសុខភាព ការអប់រំ និងឱកាសការងារ។ |
| ២ | សមធម៌ | សំដៅដល់ភាពសមរម្យនៃការផ្ដល់ជូន ឬទទួលបានអ្វីមួយ ដែលកម្រិតនៃការផ្ដល់ជូន ឬទទួលបាននោះ ត្រូវបានកំណត់ដោយផ្អែកលើចរិតលក្ខណៈនៃបុគ្គលនីមួយៗ។ |
| ៣ | សមភាព | សំដៅដល់ភាពស្មើគ្នានៃការផ្ដល់ជូន ឬទទួលបានអ្វីមួយដោយមិនផ្អែកលើចារិកលក្ខណៈនៃបុគ្គលនីមួយៗនោះឡើយ។ |
| ៤ | មរតកវប្បធម៌ | សំដៅដល់កេរ្ដិ៍តំណែលពីដូនតាយើងដែលទ្រទ្រង់នូវការសាបព្រោះបណ្ដុះពូជអោយលេចចេញជាលទ្ធផលផ្លែផ្កា។ |
| ៥ | បេតិកភ័ណ្ឌ | សំដៅដល់សំណុំទីកន្លែង និងវត្ថុទាំងឡាយណាដែលគេរក្សាទុកឱ្យគង់វង្ស ដើម្បីជាប្រយោជន៍ដល់កូនចៅជំនាន់ក្រោយៗ។ |

### ការពន្យល់បន្ថែមលម្អិតនៃពាក្យ "បេតិកភ័ណ្ឌ"

បេតិកភ័ណ្ឌត្រូវបានគេបែងចែកជាពីរធំៗដែលរួមមានបេតិកភណ្ឌវប្បធម៌ និងបេតិកភ័ណ្ឌធម្មជាតិ

- បេតិកភណ្ឌវប្បធម៌រូបិយ៍ (ឧទាហរណ៍៖ វិមានឯករាជ្យ ប្រាសាទអង្គរ....)
- បេតិកភណ្ឌវប្បធម៌អរូបិយ៍ (ឧទាហរណ៍៖ ប្រពៃណី ភាសា សិល្បៈ)

➢ បេតិកណ្ឌធម្មជាតិ (ឧទាហរណ៍៖ ទិដ្ឋភាព ឬសម្រស់ដែលកើតចេញពីធម្មជាតិ វាអាចកើតពីបាតុភូតធម្មជាតិដែលមានសោភ័ណ្ឌភាព មានទីតាំងច្បាស់លាស់ដែលជាជម្រកសត្វទាំងលើគោក និងក្នុងទឹក ព្រមទាំងមានតម្លៃជាសកល និងមានលក្ខណៈជាវិទ្យាសាស្ត្រ និងភូគព្ភសាស្ត្រ។

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃការចូលរួមចំណែកដល់សុខុមាលភាពសង្គម មានសូចនាករលំអិតចំនួន ០៤ ដែលរួមមានដូចខាងក្រោមនេះ៖

**១.ថែរក្សាភាពថ្លៃថ្នូររបស់សហគមន៍មូលដ្ឋាន**

**២. ផលប្រយោជន៍ត្រូវបានចែករំលែកដោយសមធម៌**

**៣.ការតភ្ជាប់ទៅនឹងសេដ្ឋកិច្ចតំបន់**

**៤.មរតកវប្បធម៌ត្រូវបានថែរក្សា និងផ្តល់តម្លៃ**

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ អាចមាន ០៣ករណីផ្សេងៗគ្នាដូចជា "**វិធានការលើកទឹកចិត្ត វិធានការជម្រុញឱ្យអនុវត្ត និងជំនួយរបស់គម្រោងផ្សេងៗ**" ដែលនេះ ទាមទារឱ្យមានយន្តការគ្រប់គ្រងច្បាស់លាស់មួយ ដើម្បីអាចដឹកនាំសហគមន៍ឆ្ពោះទៅសម្រេចបាននូវសុខុមាលភាពនៅក្នុងសហគមន៍ប្រកបដោយភាពជោគជ័យ។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានដូចខាងក្រោម៖

**<u>ករណីទី១៖</u>** ជាប្រភេទនៃ "**វិធានការលើកទឹកចិត្តដល់ប្រជាពលរដ្ឋសហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមអភិវឌ្ឍសហគមន៍

- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីលទ្ធផលដែលសម្រេចបាននាពេលកន្លងមក

**<u>ករណីទី២៖</u>** ជាប្រភេទនៃ "**វិធានការជម្រុញឱ្យអនុវត្តក្នុងសហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមក្នុងការអភិវឌ្ឍសហគមន៍ទាំងអស់គ្នា
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ

**<u>ករណីទី៣៖</u>** ជាប្រភេទនៃ "**ជំនួយរបស់គម្រោងផ្សេងៗនៅក្នុងសហគមន៍**" ដែលមានគោលបំណងចូលរួមចំណែកដល់ការថែទាំសុខុមាលភាពក្នុងសហគមន៍មូលដ្ឋាន។ ក្នុងករណីនេះ ត្រូវបានបែងចែកជា ០៣ផ្នែកបន្ថែមទៀតដែលរួមមានដូចជា៖

**ផ្នែកទី១៖** ប្រសិនបើមានគម្រោងណាមួយបានចូលរួមចំណែកដល់ការថែទាំសុខុមាលភាពក្នុងសហគមន៍ ហើយបានបញ្ចប់គម្រោងនោះចប់សព្វគ្រប់។

- បង្ហាញពីរបាយការណ៍បូកសរុបលទ្ធផលដែលបានអនុវត្តគម្រោងនោះកន្លងមក

**ផ្នែកទី២៖** ប្រសិនបើមានគម្រោងណាមួយត្រូវបានដាក់ឱ្យអនុវត្តរួចរាល់ ហើយបាននឹងកំពុងបន្តរហូតមកដល់ថ្ងៃស្នើសុំចូលរួមប្រឡងប្រណាំង

- បង្ហាញពីរបាយការណ៍ស្តីពីយន្តការក្នុងការអនុវត្តគម្រោង និងទិដ្ឋភាពផ្សេងៗ
- បង្ហាញពីវត្តមានអ្នកទទួលខុសត្រូវលើការអនុវត្តគម្រោងនេះ
- បង្ហាញពីរបាយការណ៍អនុវត្តគម្រោងនេះ

**ផ្នែកទី៣៖** ប្រសិនបើរាល់គម្រោងដែលមានកំពុងតែស្ថិតនៅជាផែនការនៅឡើយ

- បង្ហាញពីព័ត៌មានគំរោងទាំងអស់ដែលមាន
- បង្ហាញពីវត្តមានក្រុមការងារទទួលខុសត្រូវលើការអនុវត្តគម្រោងនេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែង

ខាងក្រោមនេះ ជាតារាងបង្ហាញពីចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង០៣ខាងលើនេះ

<table>
<tr><th colspan="4">តារាងបំពេញលក្ខណ្ឌតម្រូវ<br>នៃសូចនាករគោលនៃការរួមចំណែកដល់សុខុមាលភាពសង្គម</th></tr>
<tr><th colspan="4">ករណីទី១៖ ជាប្រភេទនៃ "វិធានការលើកទឹកចិត្ត"</th></tr>
<tr><td>ល.រ</td><td>លក្ខខណ្ឌ</td><td>ការបំពេញលក្ខខណ្ឌ</td><td>ភស្តុតាងបញ្ជាក់</td></tr>
<tr><td>១</td><td>វត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន</td><td>រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា</td><td>• មានគោលការណ៍ណែនាំក្នុងគោលបំណងដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា</td></tr>
<tr><td>២</td><td>វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ</td><td>រៀបចំ និងចាត់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ</td><td>• សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ</td></tr>
<tr><td>៣</td><td>លទ្ធផលដែលសម្រេចបាននាពេលកន្លងមក</td><td>រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមជាមួយនឹងយន្តគ្រប់គ្រងដែលបានដាក់ចេញ</td><td>• មានបញ្ជីឈ្មោះរាយនាម[2] ក្រុមការងារពាក់ព័ន្ធដែលបានចូលរួម និងមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់</td></tr>
<tr><th colspan="4">ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"</th></tr>
<tr><td>១</td><td>វត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន</td><td>រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា</td><td>• មានសេចក្តីសម្រេច គោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា<br>• មានសេចក្តីប្រកាសជាផ្លូវការ</td></tr>
<tr><td>២</td><td>វត្តមាននៃក្រុមការងារទទួលខុស</td><td>រៀបចំ និងចាត់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារនេះ</td><td>• សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការ</td></tr>
</table>

[2] តារាងទី០២

| | | | |
|---|---|---|---|
| | ត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | | ចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ | ធ្វើការបែកចែកជាក្រុមការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | • មានបញ្ជីឈ្មោះរាយនាម(3)ក្រុមការងារចូលរួម មានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| | និង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព(4)របស់អ្នកទទួលខុសត្រូវលើការងារនេះ |
| | និង | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍<br>• រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |
| **ករណីទី៣៖ ជាប្រភេទនៃ “វិធានការជម្រុញឱ្យអនុវត្ត”** | | | |
| **ផ្នែកទី១៖ គម្រោងចប់សព្វគ្រប់** | | | |
| ១ | របាយការណ៍លទ្ធផលដែលទទួលបានពីការអនុវត្តគម្រោង | រៀបចំជារបាយការណ៍លទ្ធផលមួយដែលបានបង្ហាញអំពីការវាយតម្លៃរបស់អ្នកអនុវត្តគម្រោងនេះ | • របាយការណ៍លទ្ធផលដែលមានការបញ្ជាក់ពីអ្នកទទួលខុសត្រូវអនុវត្តគម្រោង ឬប្រធានសហគមន៍ |
| **ផ្នែកទី២៖ គម្រោងកំពុងបន្តការអនុវត្ត** | | | |
| ១ | របាយការណ៍ស្តីពីយន្តការអនុវត្តគម្រោង និងទិដ្ឋភាពផ្សេងៗ | រៀបចំជារបាយការណ៍រាយការណ៍លំអិតអំពីយន្តការអនុវត្តគម្រោងនោះ | • របាយការណ៍ស្តីពីយន្តការអនុវត្តគម្រោងដែលមានការបញ្ជាក់សុពលភាពពីអ្នកទទួលខុសត្រូវអនុ |

[3] តារាងទី០២

[4] តារាងទី០៣

| | | | |
|---|---|---|---|
| | | | វត្តគម្រោងនោះ ឬអាជ្ញាធរមានសមត្ថកិច្ច |
| ២ | វត្តមានក្រុមការងារទទួលខុសត្រូវ | រៀបចំឱ្យមានអ្នកទទួលខុសត្រូវដែលមានសមាសភាព និងយន្តការគ្រប់គ្រង់ក្នុងការអនុវត្តគម្រោងនេះ | • សេចក្ដីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្ដីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | របាយការណ៍វាតម្លៃការអនុវត្តគម្រោង | រៀបចំជារបាយការណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តគម្រោង | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍ |
| **ផ្នែកទី៣៖ គម្រោងកំពុងស្ថិតក្នុងផែនការ** | | | |
| ១ | ព័ត៌មានអំពីគម្រោងទាំងអស់ដែលមាន | ធ្វើបញ្ជីសម្រង់សិត្ថិរាល់គម្រោងទាំងអស់ដែលមាន | • តារាងសម្រង់ស្ថិតិ[5]ដែលមានការបញ្ជាក់ពីប្រធានសហគមន៍ |
| ២ | វត្តមានក្រុមការងារទទួលខុសត្រូវលើការអនុវត្តគម្រោង | រៀបចំឱ្យមានជាអង្គភាពមួយដែលមានសមាសភាព និងយន្តការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងនេះ | • សេចក្ដីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្ដីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុត្តជាក់ស្ដែង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព[6]របស់អ្នកទទួលខុសត្រូវលើការងារអនុវត្តគម្រោងនេះ |
| | និង | រៀបចំជារបាយការណ៍បូកសរុបការងារប្រចាំខែ | • របាយការណ៍បូកសរុបការងារដែលមានជាការចុះហត្ថលេខា និងការបញ្ជាក់សុពលភាពពីប្រធានសហគមន៍ |

[5] តារាងទី០៤

[6] តារាងទី០៣

| | | | |
|---|---|---|---|
| | | | • រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលនៃការចូលរួមចំណែកដល់សុខុមាលភាពសង្គម សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **"កម្រិតមធ្យម"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់បំផុត"** |
|---|---|---|---|---|---|
| ២.ការចូលរួមចំណែកដល់សុខុមាលភាពសង្គម | **៤** | **១៨** | **៨** | **៥** | **៥** |

សម្រាប់និតិវិធីក្នុងការផ្តល់ពិន្ទុវាយតម្លៃសហគមន៍ទេសចរណ៍ ត្រូវបានចែកចេញជា០៣ចំនុចរួមមាន៖




⚠ **<u>សំគាល់</u>៖** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

# ៣ ស្ទូចនាករគោលនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តភាព

## កម្មវត្ថុនៃស្ទូចនាករការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តភាព

វិស័យទេសចរណ៍សហគមន៍ បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ ទន្ទឹមនេះ ការចូលរួមចំណែកនេះ ក៏ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសលើផលប៉ះពាល់នៃការបង្កើតសំណល់ដោយភ្ញៀវទេសចរ និងផលប៉ះពាល់នៃការគ្រប់គ្រងទុកដាក់សំណល់មិនត្រឹមត្រូវផងដែរ។

ការផ្តួចផ្តើមនៃស្ទូចនាករនេះ គឺជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពផ្នែកបរិស្ថាន និរន្តរភាពបរិស្ថាន និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ឱ្យមានលក្ខណៈល្អប្រសើរឡើង។ ម្យ៉ាងវិញទៀត ក៏បានចូលរួមលើកទឹកចិត្តឱ្យប្រជាសហគមន៍មូលដ្ឋានផ្ទាល់អនុវត្តគោលការណ៍ណែនាំស្តីពី **ក.ប.ក** (3R ឬការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ) ដែលរួមចំណែកដល់គោលនយោបាយនៃការគ្រប់គ្រងសំណល់ ពិសេសសំណង់ជាថង់ប្លាស្ទិក។ កិច្ចការងារទាំងអស់នេះ គឺចាំបាច់ទាមទារឱ្យមានការចូលរួមពីគ្រប់មូលដ្ឋាន និងត្រួតពិនិត្យវាយតម្លៃរាល់សកម្មភាពនានាដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យបានយ៉ាងណាបាននូវការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះផងដែរ។

### ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | បរិស្ថាន | សំដៅដល់គឺជាមជ្ឈដ្ឋាន ដែលនៅជុំវិញខ្លួនយើង ឬជារបស់របរវត្ថុ ដែលនៅលោកព័ទ្ធយើង ហើយមានឥទ្ធិពលដល់ជីវិត និងការលូតលាស់របស់បណ្តាភាវៈ។ |
| ២ | ការអភិរក្ស | សំដៅដល់ដំណើរការនៃការថែរក្សាតំបន់ ឬកន្លែងណាមួយដើម្បីការពារការថែរក្សាភាពដើម និងការកសាងឡើងវិញ។ |
| ៣ | និរន្តរភាព | សំដៅដល់ ភាពឥតចន្លោះ, ភាពឥតស្រាក, ភាពដែលមានជានិច្ច, សេចក្តីដែលកើតមាន, ឥតឈប់ឈរ។ |
| ៤ | ចីរភាព | សំដៅដល់ភាពដែលយូរអង្វែង , កាលដែលវែងឆ្ងាយ ឬការប្រកបដោយចីរភាព (អ្វីដែលប្រកបដោយភាពរីកចម្រើនទៅមុខ)។ |

| | | |
|---|---|---|
| ៥ | សំណល់រឹង | សំដៅដល់វត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់របរកំទិចកំទីដែលលែងត្រូវការប្រើប្រាស់ហើយដែលត្រូវបានគេបោះបង់ចោល។ |
| ៦ | សំរាម | សំដៅដល់ផ្នែកមួយនៃសំណល់រឹងដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អគារសាធារណៈ រោចក្រ។ល។ |
| ៧ | សំណល់សរីរាង្គ | សំដៅដល់កាកសំណង់ផ្ទះបាយ ឬបន្លែធម្មជាតិផ្សេងៗដែលមិនមានសារធាតុគីមី និងមិនមានគ្រោះថ្នាក់អ្វីទាំងអស់។ |
| ៨ | គោលការណ៍ 3R | សំដៅដល់ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (Reduce, Reuse, Recycle) |

## ការពន្យល់បន្ថែមលម្អិតនៃពាក្យ "បរិស្ថាន"

បរិស្ថានត្រូវបានបែងចែកជា០៣ផ្នែក ដែលរួមមានដូចជា៖

- បរិស្ថានធម្មជាតិ៖ សំដៅដល់បរិស្ថានមានជីវិត និងគ្មានជីវិត (ទឹក ដី ភ្លើង ខ្យល់ ភ្នំ ព្រៃឈើ) និងបរិស្ថានមានជីវិត មនុស្សសត្វ និងរុក្ខជាតិ។
- បរិស្ថានមនុស្ស៖ សំដៅដល់សំណុំលក្ខខណ្ឌរូបសាស្ត្រ គីមី ជីវសាស្ត្រ រួមជាមួយកត្តាសង្គមនានាដែលកំណត់ ការរស់នៅរបស់មនុស្ស ក្នុងពេលជាក់លាក់ណាមួយ ។
- បរិស្ថានសង្គម៖ សំដៅដល់សំណង់អាគារហេដ្ឋារចនាសម្ព័ន្ធ ទីក្រុង ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធអេកូឡូស៊ីរោងចក្រ សហគ្រាស សិប្បកម្ម សួនច្បារ វិមានរដ្ឋសភា វិមានរាជរដ្ឋាភិបាល និងសកម្មភាពសង្គមផ្សេងៗទៀត។

## ការពន្យល់បន្ថែមលម្អិតនៃពាក្យ "៥ Rs"

- បដិសេធមិនប្រើប្រាស់ (Refuse)៖ មិនទទួលយកការប្រើប្រាស់ប្លាស្ទិក ដូចជា បំពង់បឺតប្លាស្ទិក កាបូបប្លាស្ទិក និងប្រអប់ស្នោដាក់អាហារតាមដែលអាចធ្វើបាន។
- កាត់បន្ថយការបង្កើតប្លាស្ទីក (Reduce)៖ ព្យាយាមកាត់បន្ថយប្លាស្ទីកដោយសម្រេចចិត្តទិញរបស់ដែលមិនប្រើប្លាស្ទីកឲ្យបានច្រើន។
- កែច្នៃឡើងវិញ (Recycle)៖ កែច្នៃប្លាស្ទីកដើម្បីប្រើប្រាស់ឡើងវិញ ហើយនឹងចោលសំរាមប្លាស្ទីកនៅក្នុងធុងសំរាមកែច្នៃឡើងវិញ។
- ប្រើឡើងវិញរាល់ប្លាស្ទិក (Reuse)៖ ប្រើប្រាស់វត្ថុដែលជាប្លាស្ទីកឡើងវិញ មុខពេលសម្រេចចិត្តប្រើប្រាស់ប្លាស្ទីកថ្មី

- រំលឹកអ្នកដទៃ (Remind)៖ ចូលរួមរំលឹកអ្នកនៅជុំវិញខ្លួនយើងអំពីវិធីកាត់បន្ថយប្លាស្ទិកតាម 4Rs ខាងលើ ហើយឲ្យពួកគាត់ពិចារណាអំពីសកម្មភាពនៃការប្រើប្រាស់ប្លាស្ទិករបស់ពួកគាត់ឡើងវិញ។

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តភាព មានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖

១. ការអភិរក្ស និងគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព

២. សកម្មភាពអភិរក្សដើម្បីធ្វើឱ្យបរិស្ថានល្អប្រសើរ

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ “**ប្រសិទ្ធិភាពការងារ**” ដែលនេះ ទាមទារឱ្យមានយន្តការគ្រប់គ្រងច្បាស់លាស់មួយ ដើម្បីដឹកនាំសហគមន៍ឆ្ពោះទៅរកភាពស្អាត និងបៃតងបាន។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន៤ ដូចខាងក្រោម៖

- ផ្តល់ព័ត៌មានអំពីចំនួនទីកន្លែង និងសកម្មភាពដែលបានអនុវត្តក្នុងការអភិរក្ស និងគ្រប់គ្រងបរិស្ថានបានល្អប្រសើរនៅក្នុងសហគមន៍មូលដ្ឋាន
- បង្ហាញពីវត្តមាននៃយន្តការចុះត្រួតពិនិត្យ និងអប់រំណែនាំដល់ប្រជាសហគមន៍
- បង្ហាញពីវត្តមាននៃអង្គភាពទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍ទាំងអស់នេះ

ខាងក្រោមនេះ ជាតារាងបង្ហាញពីចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង០៤ខាងលើនេះ

| តារាងបំពេញលក្ខណ្ឌគម្រូង<br>នៃសូចនាករគោលការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃផ្តល់ព័ត៌មានអំពីចំនួនទីកន្លែង និងសកម្មភាព ដែលបានអនុវត្តក្នុងការអភិរក្ស | សម្រង់ស្ថិតិអំពីទីកន្លែងដែលអភិរក្ស និងគ្រប់គ្រងបរិស្ថានបានល្អមាននៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួនផ្ទាល់ | • តារាងសម្រង់ស្ថិតិ[7]ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬប្រធានសហគមន៍មូលដ្ឋាន |
| | និង | រៀបចំជាផែនទីតំបន់សហគមន៍ដែលមានបញ្ជាក់ពីទីកន្លែងទាំងអស់នោះ | • ផែនទីរដ្ឋបាលដែលមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ឬប្រធានសហគមន៍មូលដ្ឋាន |
| ២ | វត្តមាននៃយន្តការចុះត្រួតពិនិត្យ និងអប់រំណែនាំដល់ប្រជាសហគមន៍ | រៀបចំជាវិធាន យន្តការ ឬគោលការណ៍ណែនាំនានាសម្រាប់ការអនុវត្តការត្រួតពិនិត្យ និងការចុះអប់រំណែនាំដល់ប្រជាសហគមន៍ | • នីតិវិធីផ្សេងៗដែលមានតម្លៃស្មើស្តីពីការកំណត់យន្តការត្រួតពិនិត្យ និងចុះអប់រំណែនាំ |
| ៣ | វត្តមាននៃអង្គភាពទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធានការទាំងអស់នេះ | រៀបចំឱ្យមានជាក្រុមការងារទទួលខុសត្រូវក្នុងការចុះតាមដាន និងអនុវត្តការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬប្រកាសនានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងសមាសភាពក្រុមការងារនេះ |
| ៤ | សកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍ទាំងអស់នោះ | រៀបចំធ្វើតារាងបែងចែកជាក្រុមការងារដើម្បីចុះត្រួតពិនិត្យការងារទាំងអស់នេះ | • បញ្ជីរាយនាម[8]ក្រុមការងារដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋាន ឬអាជ្ញាធរមានសមត្ថកិច្ច |

[7] តារាងទី០៥

[8] តារាងទី០១

| | | | |
|---|---|---|---|
| | និង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព[9]របស់អង្គភាពដែលទទួលខុសត្រូវរាល់ការងារទាំងអស់នេះ |
| | និង | រៀបចំចងក្រងជារបាយការណ៍បូកសរុបការងារជាប្រចាំ | • របាយការណ៍បូកសរុបការងារដែលមានចុះហត្ថលេខាពីប្រធានសហគមន៍ ឬអាជ្ញាធរមានសមត្ថកិច្ច<br>• រូបថត រូបភាព ឬខ្សែវីដេអូ ឬឯកសារផ្សេងៗដែលបញ្ជាក់អំពីរាល់សកម្មភាពជាក់ស្តែង |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយនិរន្តភាព សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **“កម្រិតមធ្យម”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់បំផុត”** |
|---|---|---|---|---|---|
| ៣. ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ | **២** | **១២** | **៦** | **៣** | **៣** |




[9] តារាងទី០៣

# ៤ សូចនាករគោល នៃការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងទេសចរ

## កម្មវត្ថុនៃសូចនាករការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងទេសចរ

វិធីសាស្ត្រក្នុងការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងភ្ញៀវទេសចរគឺជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយក្នុងការបង្កើនភាពស្និទស្នាល និងជាការផ្ទេរការយល់ដឹង ឬព័ត៌មានផ្សេងៗពីគ្នាទៅវិញទៅមក។ ដើម្បីអភិវឌ្ឍសហគមន៍ឆ្ពោះទៅរកភាពជោគជ័យបាន ដូចនេះគឺអាស្រ័យទៅលើការពេញចិត្តរបស់ភ្ញៀវទេសចរ រួមផ្សំជាមួយនឹងបទពិសោធន៍ល្អៗដែលពួកគេទទួលបានពួកប្រជាសហគមន៍មូលដ្ឋានផ្ទាល់ តាមរយៈការប្រាស្រ័យទាក់ទងល្អៗទាំងអស់នេះ។

| ក. និយមន័យនៃពាក្យគន្លឹះ | | |
|---|---|---|
| **ល.រ** | **ពាក្យគន្លឹះ** | **សេចក្តីពន្យល់នៃពាក្យគន្លឹះ** |
| ១ | ទេសចរ | សំដៅដល់បុគ្គលទាំងឡាយជាជនជាតិកម្ពុជា ឬជនបរទេសដែលមកដល់តំបន់ផ្សេងៗក្រៅពីបរិយាកាសប្រកតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ ដើម្បីសម្រាកលំហែកម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះទេ។ |
| ២ | ទំនាក់ទំនង | សំដៅដល់ដំណើរការមួយ ហើយដំណើរការនោះមិនត្រឹមតែពាក់ព័ន្ធនឹងការបញ្ជូន និងទទួលសារតែថែមទាំងរួមបញ្ចូលការស្តាប់ដោយផ្ទាល់ជាមួយភ្ញៀវ និងបកស្រាយពន្យល់ និងឆ្លើយតបទៅភ្ញៀវ និងអាចមានសកម្មភាពដែលពាក់ព័ន្ធជាមួយភ្ញៀវផ្សេងៗទៀត។ |
| ៣ | សហគមន៍ទេសចរណ៍ | សំដៅដល់គឺជាទំរង់មួយនៃវិស័យទេសចរណ៍ ដែលសំដៅដល់ទីតាំង ឬកន្លែងទាក់ទាញទេសចរណ៍ ដែលរៀបចំដោយសហគមន៍មូលដ្ឋានខ្លួនឯកផ្ទាល់ ឬដោយមានកិច្ចសហប្រតិបត្តិការដើម្បីពង្រឹងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍ និងបម្រើផលប្រយោជន៍ ប្រជាពលរដ្ឋមូលដ្ឋានតាមរយៈការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព។ |

## ការពន្យល់បន្ថែមលម្អិតនៃពាក្យ "ទេសចរ"

- **ទេសចរណ៍៖** សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងក្រៅពីបរិយាកាសប្រក្រតីរបស់គេសម្រាប់រយៈពេលកំណត់មួយដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។
- **ទេសចរអន្តរជាតិ៖** សំដៅដល់បុគ្គលដែលធ្វើដំណើរចេញក្រៅប្រទេសកំណើតរបស់ខ្លួនលើសពី២៤ម៉ោង ដោយត្រូវស្នាក់នៅទីនោះលើសពី០១យប់ ប៉ុន្តែមិនលើសពីរយៈពេល០១ឆ្នាំ ហើយពុំបានធ្វើសកម្មភាពកាងារសម្រាប់សេដ្ឋកិច្ច និងជីវភាពផ្ទាល់ខ្លួនទេក្នុងគោលបំណងៈ វិស្សមកាល, ជំនួយ និងអាជីវកម្ម, ការលំហែកម្សាន្ត, ការព្យាបាលសុខភាព, សាសនា ធម្មយាត្រា, ចូលរួម ឬរួមចំណែកក្នុងព្រឹត្តិការណ៍ទេសចរណ៍ និងកីឡាទេសចរណ៍ផ្សេងៗ, សកម្មភាពធ្វើជំនួញ និងវិជ្ជាជីវៈ, ចូលរួមក្នុងសន្និបាត កិច្ចប្រជុំសន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ពិព័រណ៌ទេសចរណ៍។ល។ ទេសចរអន្តរជាតិត្រូវបានគេបែងចែកជា០២ផ្នែករួមមាន៖
  - **ទេសចរចូលក្នុងប្រទេស** (Inbound Tourists) សំដៅដល់ប្រជាជននៃប្រទេសមួយដែលបានធ្វើដំណើរជាលក្ខណៈទេសចរណ៍ ចូលទៅប្រទេសផ្សេងទៀត ដែល មិនមែនប្រទេសកំណើតរបស់ខ្លួនក្នុងគោលដៅទេសចរណ៍។
  - **ទេសចរចេញក្រៅប្រទេស** (Outbound Tourists) សំដៅដល់ប្រជាជននៃប្រទេសមួយដែលបានធ្វើដំណើរជាលក្ខណៈទេសចរណ៍ទៅប្រទេសផ្សេងៗទៀត ដែលមិនមែនជាប្រទេសកំណើតរបស់ខ្លួនក្នុងគោលដៅទេសចរណ៍។
- **ទេសចរក្នុងស្រុក៖** សំដៅដល់បុគ្គលដែលធ្វើដំណើរទៅឆ្ងាយពីផ្ទះរបស់ខ្លួន ក្នុងប្រទេសរបស់ខ្លួនលើសពី២ម៉ោង ដោយត្រូវស្នាក់នៅទីនោះលើសពី០១យប់ ក្នុងតំបន់ដែលខ្លួនមកដល់ក្នុងគោលដៅទេសចរណ៍ក្នុងប្រទេស ក្នុងរយៈពេលមិនលើសពី០១ឆ្នាំ និងមិនបានបំពេញការងាររកប្រាក់ចំណូលក្នុងតំបន់ទេ (បុគ្គលដែលធ្វើការផ្លាស់ប្តូរទីកន្លែងរស់នៅក្នុងប្រទេសរបស់ខ្លួន មិនអាចចាត់ទុកថាជាទេសចរបានឡើង)។

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងទេសចរមានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖

**១. ការទំនាក់ទំនងរវាងទេសចរ និងសហគមន៍**

**២. សកម្មភាពទំនាក់ទំនងរវាងទេសចរ និងសហគមន៍**

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ “**ប្រសិទ្ធិភាពការងារទំនាក់ទំនង**” ដែលនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយស្មារតីប្រុងប្រយ័ត្ន ដើម្បីសហគមន៍អាចឈានឆ្ពោះទៅរកប្រជាប្រិយភាព និងការចាប់អារម្មណ៍ពីភ្ញៀវទេសចរ។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន០៣ ដូចខាងក្រោម៖

- ព័ត៌មានអំពីចំនួនប្រជាសហគមន៍មូលដ្ឋាននាពេលបច្ចុប្បន្នដែលបាននឹងកំពុងរស់នៅក្នុងសហគមន៍
- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តឱ្យប្រជាសហគមន៍មានទំនាក់ទំនងល្អជាមួយភ្ញៀវ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់ប្រជាសហគមន៍មូលដ្ឋាន

ខាងក្រោមនេះ ជាតារាងបង្ហាញពីចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង០៣ខាងលើនេះ

| តារាងបំពេញលក្ខណ្ឌតម្រូវ<br>នៃសូចនាករគោលការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍<br>និងទេសចរ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមានព័ត៌មានអំពីចំនួនប្រជាសហគមន៍មូលដ្ឋាននាពេលបច្ចុប្បន្ន | ធ្វើបញ្ជីសម្រង់ស្ថិតិអំពីចំនួនប្រជាជនដែលកំពុងរស់នៅក្នុងសហគមន៍មូលដ្ឋាន | • តារាងសម្រង់ស្ថិតិ[10]ដែលបានបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| ២ | វត្តមាននៃវិធានការលើកទឹកចិត្តឱ្យប្រជាសហគមន៍មានទំនាក់ទំនងល្អជាមួយភ្ញៀវ | រៀបចំជាផែនការ ឬគោលការណ៍លើកទឹកចិត្តចំពោះការចូលរួមរបស់ប្រជាសហគមន៍មូលដ្ឋាន | • និតិវិធីនានាដែលបានជម្រុញឱ្យមានការលើកទឹកចិត្តចូលរួមរបស់ប្រជាសហគមន៍មូលដ្ឋាន |
| ៣ | សកម្មភាពអនុវត្តជាក់ស្តែងរបស់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំជាតារាងផែនការសកម្មភាពផ្សេងៗ ដើម្បីឱ្យប្រជាជនអាចមានឱកាសក្នុងការទំនាក់ទំនងជាមួយភ្ញៀវទេសចរ | • តារាងផែនការសកម្មភាព[11]របស់ក្រុមការងារទទួលបន្ទុកលើការងារនេះ |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលនៃការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍ និងទេសចរ សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

[10] តារាងទី០៦

[11] តារាងទី០៧

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **“កម្រិតមធ្យម”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់បំផុត”** |
|---|---|---|---|---|---|
| ៤. ការជំរុញលើកទឹកចិត្តនូវការទំនាក់ទំនងរវាងសហគមន៍និងទេសចរ | **២** | **១៣** | **៣** | **៤** | **៦** |



១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា ***(តារាងភស្តុតាងបញ្ជាក់)***



៣. ការប្រមូលរូបភាពសកម្មភាពនានា ***(តារាងភស្តុតាងបញ្ជាក់)***

⚠ **សំគាល់៖** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

# ៥ សូចនាករគោលទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៍

## កម្មវត្ថុនៃសូចនាករទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៍

ការពង្រឹងគុណភាព និងសេវាកម្មមគ្គុទ្ទេសក៍ជាផ្នែកមួយដ៏សំខាន់ផងដែរ ក្នុងការចូលរួមអភិវឌ្ឍសហគមន៍ តាមរយៈការចូលរួមជំរុញដល់ការទាក់ទាញភ្ញៀវទេសចរឱ្យមាលេងកម្សាន្តនៅសហគមន៍ ជាពិសេស ការអធិប្បាយអំពីសក្តានុពលទេសចរណ៍ និងធនធានដែលមាននៅតាមសហគមន៍ទេសចរណ៍នានា។ ជាមួយគ្នានេះ ក៏បានជំរុញបង្កើតឱ្យមានមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងស្រុកសម្រាប់ភ្ញៀវទេសចរផងដែរ។ ទន្ទឹមនេះ ការពង្រឹងគុណភាព និងសេវាកម្មផ្សេងៗគឺចាំបាច់ត្រូវតែឆ្លើយតបទៅនឹងស្តង់ដាដែលក្រសួងទេសចរណ៍បានដាក់ចេញ និងឈានទៅដល់ការអនុវត្តនូវស្តង់ដាអាស៊ាន។

### ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ៥.១ | មគ្គុទ្ទេសក៍ | សំដៅដល់បុគ្គលប្រកបអាជីពជាអ្នកទទួលជូន ថែរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទំលាប់ និងសេដ្ឋកិច្ចសង្គមនៃទីកន្លែងទស្សនា។ |
| ៥.១ | នាំអ្នកក្រុមភ្ញៀវទេសចរ | សំដៅដល់បុគ្គលដែលការីទេសចរណ៍បានចាត់ឱ្យបំពេញតួនាទី និងភារកិច្ចជាអ្នកនាំក្រុមទេសចរ ក្នុងរយៈពេលនៃការប្រើប្រាស់ខ្សែទស្សនកិច្ចជួយសម្របសម្រួល និងបង្កភាពងាយស្រួលដល់ការអនុវត្ត ការងារនៃមគ្គុទ្ទេសក៍ទេសចរណ៍។ |
| | សេចក្តីអធិប្បាយ | សំដៅដល់ការពន្យល់សេចក្តីដោយមានគ្រឿងសំអាង ឬសេចក្តីពន្យល់ ដែលមានភស្តុតាង។ |
| ៥.១ | អ្នកឧទ្ទេសនាម | សំដៅដល់បុគ្គលដែលត្រូវបានប្រគល់ភារកិច្ចឱ្យពន្យល់ អធិប្បាយជូនភ្ញៀវនៅតាមប្រាសាទ ឬតាមសារមន្ទីរ។ |
| | ជំនាញក្នុងការបកស្រាយ | សំដៅដល់ការយល់ដឹងដែលរួមបញ្ចូលនូវសមត្ថភាពជាច្រើន មិនមែនត្រឹមតែសមត្ថភាពភាសាទេ ប៉ុន្តែធ្វើការបកស្រាយប្រកបប្រសិទ្ធភាព។ |
| ៥.១ | សេវាកម្ម | សំដៅដល់ការងារមួយដែលធ្វើឡើងដោយភាគីម្ខាង ហើយភាគីម្ខាងទៀតជាអ្នកទទួលបានសារៈប្រយោជន៍ តាមរយៈការជួយសម្រួល ឬបម្រើសេវាកម្មផ្សេងៗ។ |

| | | |
|---|---|---|
| ៥.១.២ | ជីវៈចម្រុះ | ប្រភេទសត្វ និងរុក្ខជាតិច្រើនប្រភេទដែលមាននៅក្នុងបរិស្ថានធម្មជាតិ។ |
| ៥.១.៣ | ស្តង់ដា | គឺសំដៅដល់ពាក្យដែលកម្ចីមកពីភាសាបារាំង Standard ដែលមានន័យថានិយាម ឬបទដ្ឋាន។ |

### ការពន្យល់បន្ថែមលម្អិតនៃពាក្យ "មគ្គុទ្ទេសក៍"

- **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ពិសេស៖** សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលត្រូវបានអនុញ្ញាតឱ្យបំពេញការងារនៅតាមប្រាសាទ ឬសារមន្ទីរដែលជាបេតិកភណ្ឌថ្នាក់ជាតិ ឬថ្នាក់ពិភពលោក។
- **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ជាតិ៖** សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលមានអាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់ជាតិដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅគ្រប់គោលដៅទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់តំបន់៖** សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលមានអាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់តំបន់ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍ក្នុងតំបន់មួយចំនួននៃ ព្រះរាជាណាចក្រកម្ពុជា។
- **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ៖** សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលមានអាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវទៅតាមគោលដៅទេសចរណ៍តែនៅក្នុងដែនដីនៃ រាជធានីខេត្តនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។
- **មគ្គុទ្ទេសក៍ទេសចរណ៍ថ្នាក់សហគមន៍៖** សំដៅដល់មគ្គុទេសក៍ទេសចរណ៍ដែលមានអាជ្ញាបណ្ណមគ្គុទេសក៍ទេសចរណ៍ ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចនាំភ្ញៀវតែក្នុងសហគមន៍តែប៉ុណ្ណោះទេ។

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងស្តង់ដារគោលទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៍មានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖

១. ធានាឱ្យទេសចរណ៍មានគុណភាព

២. ធានាឱ្យមានជំនាញច្បាស់លាស់មគ្គុទ្ទេសក៏មូលដ្ឋាន

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ "**ប្រសិទ្ធិភាព និងគុណភាព**" ដែលនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវ ដើម្បីសហគមន៍អាចឈានឆ្ពោះទៅរកភាពជោគជ័យបាន។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន០២ ដូចខាងក្រោម៖

ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានដូចខាងក្រោម៖

**<u>ករណីទី១៖</u>** ជាប្រភេទនៃ "**វិធានការលើកទឹកចិត្តដល់ប្រជាសហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមពង្រឹងគុណភាពសេវាកម្មទេសចរណ៍
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីលទ្ធផលដែលសម្រេចបាននាពេលកន្លងមក

**<u>ករណីទី២៖</u>** ជាប្រភេទនៃ "**វិធានការជម្រុញឱ្យអនុវត្តប្រជាសហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមក្នុងការពង្រឹងសេវាកម្មទាំងអស់គ្នា
- បង្ហាញពីវត្តមាននៃអង្គភាពទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ

| តារាងបំពេញលក្ខណៈតម្រូវ<br>នៃសូចនាករគោលទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៍ | | | |
|---|---|---|---|
| **ករណីទី១៖ ជាប្រភេទនៃ "វិធានការលើកទឹកចិត្ត"** | | | |
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្ម | • មានគោលការណ៍ណែនាំ ក្នុងគោលបំណងដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្ម |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាត់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានា ដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | លទ្ធផលដែលសម្រេចបាននាពេលកន្លងមក | រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមជាមួយនឹងយន្តគ្រប់គ្រងដែលបានដាក់ចេញ | • របាយការណ៍បូកសរុបការងារដែលមានចុះហត្ថលេខាពីប្រធានសហគមន៍ |
| **ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"** | | | |
| ១ | វត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា | • មានសេចក្តីសម្រេច គោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា<br>• មានសេចក្តីប្រកាសជាផ្លូវការ |

| | | | |
|---|---|---|---|
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្ដីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្ដីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្ដែងរបស់សហគមន៍នោះ | ធ្វើការបែកចែកជាក្រុមការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | • មានបញ្ជីឈ្មោះរាយនាម[12]ក្រុមការងារទាំងអស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| | និង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព[13]របស់អ្នកទទួលខុសត្រូវលើការងារនេះ |
| | និង | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់<br>• រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលទេសចរណ៍គុណភាព និងសេវាកម្មមគ្គុទ្ទេសក៏សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **"កម្រិតមធ្យម"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់បំផុត"** |
|---|---|---|---|---|---|
| ៥. ទេសចរណ៍ | **២** | **១៩** | **៨** | **៦** | **៥** |

[12] តារាងទី០២

[13] តារាងទី០៣

| | | | | | |
|---|---|---|---|---|---|
| គុណភាព និងសេវាកម្មមគ្គុទ្ទេសក៏ | | | | | |



១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា ***(តារាង**កស្តុតាងបញ្ជាក់)*



៣. ការប្រមូលរូបភាពសកម្មភាពនានា ***(តារាង**កស្តុតាងបញ្ជាក់)*

⚠ **<u>សំគាល់៖</u>** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

## ៦ សូចនាករគោលទេសចរណ៍គុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ

## កម្មវត្ថុនៃសូចនាករទេសចរណ៍គុណភាពសេវាកម្មម្ហូបអាហារ និង ភេសជ្ជៈ

ដើម្បីពង្រឹងគុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ និងឱ្យម្ចាស់ភោជនីយដ្ឋានអាចអភិវឌ្ឍសេវាកម្មរបស់ខ្លួនប្រកបដោយគុណភាព សុវត្ថិភាព និងអនាម័យ។ ម្យ៉ាងវិញទៀត ក៏បានផ្តល់ឱកាសជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិអាចទទួលបាននូវបទពិសោធន៍ល្អៗក្នុងការបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈប្រកបដោយភាពត្រឹមត្រូវសមស្របតាមស្តង់ដា និងចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ តាមរយៈការបង្កើតប្រាក់ចំណូលដោយផ្ទាល់ និងប្រយោលទៀតផង។

### ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | ការទទួលស្គាល់គុណភាព | សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងទេសចរណ៍ ឬដែលចេញដោយសមាគមឧស្សាហកម្មទេសចរណ៍ ដើម្បីបញ្ជាក់ទទួលស្គាល់គុណភាពផលិតផល ឬសេវាកម្មទេសចរណ៍ដែលបានឆ្លើយតបទៅនឹងស្តង់ដាធានាគុណភាព កំណត់ដោយក្រសួងទេសចរណ៍។ |
| ២ | ស្លាកសញ្ញាបញ្ជាក់គុណភាព | សំដៅដល់សញ្ញាដែលកំណត់ដោយក្រសួងទេសចរណ៍ក្រោមមាត្រា២៦ នៃច្បាប់នេះ ដើម្បីសម្គាល់ពីគុណភាពនៃផលិតផល សេវាកម្មទេសចរណ៍ តម្រូវប្រើប្រាស់សម្រាប់ប្រភេទនីមួយៗ នៃអាជីវកម្មផ្សេងៗនៅក្នុងឧស្សាហកម្មទេសចរណ៍ ហើយបានឆ្លើយតបទៅនឹងស្តង់ដាធានាគុណភាពផលិតផល សេវាកម្មទេសចរណ៍។ |
| ៣ | ស្លាកសញ្ញាពិសេស | សំដៅដល់សញ្ញាដែលកំណត់ដោយក្រសួងទេសចរណ៍ក្រោមមាត្រា២៦ នៃច្បាប់នេះ ដើម្បីសម្គាល់ពីលក្ខណៈពិសេស និងគុណសម្បត្តិពិសេសផ្សេងៗទៀតនៃផលិតផលទេសចរណ៍ ពិនិត្យឃើញថាឆ្លើយតបទៅនឹងស្តង់ដាធានាគុណភាពផលិតផល សេវាកម្មទេសចរណ៍។ |
| ៤ | អេកូឡាបិល | សំដៅដល់ស្លាកសញ្ញាបរិស្ថានពិសេស ដែលកំណត់ដោយក្រសួងទេសចរណ៍ ក្រោមមាត្រា២៧ សម្រាប់ផលិតផលអេកូទេសចរណ៍។ |
| ៥ | លក្ខណៈដើម | សំដៅដល់ភាពពិតប្រាកដមិនក្លែងបន្លំ ឬភាពត្រឹមត្រូវ ដើម្បីផ្តល់ជូនភ្ញៀវនូវបទពិសោធន៍ត្រឹមត្រូវពិសេសទាក់ទងទៅនឹងធម្មជាតិ និងវប្បធម៌ក្នុងស្រុក។ |

| | | |
|---|---|---|
| ៦ | បដិសណ្ឋារកិច្ច | សំដៅដល់ពាក្យបាលីថាបដិសណ្ឋារៈ ដែលមានន័យយ៉ាងខ្លី និងងាយយល់ថាគឺជាការទទួលស្វាគមន៍ភ្ញៀវដោយភាពរួសរាយរាក់ទាក់ ទន់ភ្លន់ និងប្រកបដោយភាពកក់ក្ដៅ។ |
| ៧ | គារវកិច្ច | សំដៅដល់ការសំដែងនូវសេចក្ដីគោរព និងឱនលំទោន ជាមួយនឹងស្មារតីស្រលាញ់រាប់អានគ្នាទៅវិញទៅមក។ |

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលទេសចរណ៍គុណភាពម្ហូបអាហារ និងភេសជ្ជៈមានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖




លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ "**ប្រសិទ្ធិភាព និងគុណភាព**" ដែលនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយស្មារតីប្រុងប្រយ័ត្ន ដើម្បីសហគមន៍អាចឈានឆ្ពោះទៅរកការពង្រឹងគុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈបានល្អប្រសើរ។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន០២ ដូចខាងក្រោម៖

ដូចនេះ លក្ខខណ្ឌត្រូវសម្រាប់សូចនាករគោលនេះ រួមមានដូចខាងក្រោម៖

**ករណីទី១៖** ជាប្រភេទនៃ "**វិធានការលើកទឹកចិត្តប្រជាសហគមន៍មូលដ្ឋាន**"

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមពង្រឹងគុណភាពម្ហូបអាហារ និងភេសជ្ជៈ
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ

- បង្ហាញពីលទ្ធផលដែលសម្រេចបាននាពេលកន្លងមក

<u>**ករណីទី២៖**</u> ជាប្រភេទនៃ “**វិធានការជម្រុញឱ្យអនុវត្តប្រជាសហគមន៍មូលដ្ឋាន**”

- បង្ហាញពីវត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមក្នុងការពង្រឹងគុណភាពម្ហូបអាហារ និងភេសជ្ជៈ
- បង្ហាញពីវត្តមាននៃអង្គភាពទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ

| **តារាងបំពេញលក្ខណ្ឌគម្រូង<br>នៃសូចនាករគោលទេសចរណ៍គុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ** | | | |
|---|---|---|---|
| **ករណីទី១៖ ជាប្រភេទនៃ “វិធានការលើកទឹកចិត្ត”** | | | |
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំចងក្រងជាយន្តការវិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្ម | • មានគោលការណ៍ណែនាំក្នុងគោលបំណងដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្ម |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាត់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | លទ្ធផលដែលសម្រេចបាននាពេលកន្លងមក | រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមជាមួយនឹងយន្តគ្រប់គ្រងដែលបានដាក់ចេញ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |

| ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត" | | | |
|---|---|---|---|
| ១ | វត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា | • មានសេចក្ដីសម្រេច គោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា<br>• មានសេចក្ដីប្រកាសជាផ្លូវការ |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្ដីសម្រេច ឬលិខិតបទដ្ឋាននានា ដែលមានតម្លៃស្មើស្ដីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្ដែងរបស់សហគមន៍នោះ | ធ្វើការបែកចែកជាក្រុមការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | • មានបញ្ជីឈ្មោះរាយនាម(14) ក្រុមការងារទាំងអស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| | និង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព(15) របស់អ្នកទទួលខុសត្រូវលើការងារនេះ |
| | និង | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់<br>• រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |

[14] តារាងទី០៣

[15] តារាងទី០៤

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោល គុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **“កម្រិតមធ្យម”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់បំផុត”** |
|---|---|---|---|---|---|
| ៦. គុណភាពសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ | **២** | **២២** | **១៥** | **៥** | **២** |


១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ


២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា ***(តារាង**ភស្តុតាងបញ្ជាក់)*


៣. ការប្រមូលរូបភាពសកម្មភាពនានា ***(តារាង**ភស្តុតាងបញ្ជាក់)*

**<u>សំគាល់៖</u>** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

# ៧ សូចនាករគោលទេសចរណ៍គុណភាពកន្លែងស្នាក់នៅ

## កម្មវត្ថុនៃសូចនាករទេសចរណ៍គុណភាពកន្លែងស្នាក់នៅ

ដើម្បីពង្រឹងគុណភាពសេវាកម្មស្នាក់នៅ និងឱ្យម្ចាស់ផ្ទះស្នាក់អាចអភិវឌ្ឍសេវាកម្មផ្ទះស្នាក់របស់ខ្លួនប្រកបដោយគុណភាព សុវត្ថិភាព និងអាចពន្យាការស្នាក់នៅរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យមកសម្រាកលំហែកម្សាន្តឱ្យបានកាន់តែយូរជាងមុន។ ជាពិសេសគឺការចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ តាមរយៈការបង្កើតប្រាក់ចំណូលដោយផ្ទាល់ និងប្រយោលទៀតផង។

## ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | ផ្ទះស្នាក់សហគមន៍ | សំដៅដល់កន្លែងដែលភ្ញៀវស្នាក់នៅជាមួយគ្រួសារម្ចាស់ផ្ទះ និងទទួលបានបទពិសោធន៍ពីការ រស់នៅប្រចាំថ្ងៃនៃគ្រួសារម្ចាស់ផ្ទះ និងសហគមន៍ ដោយផ្ទាល់ ឬដោយប្រយោល។ |
| ២ | ផ្ទះស្នាក់ជនបទ | សំដៅដល់ប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅស្ថានប្រជាពលរដ្ឋនៅតាមកសិដ្ឋាន ចំការ ឬវាលស្រែតាមតំបន់ជនបទដែលម្ចាស់កសិដ្ឋាន ម្ចាស់ចំការ ឬប្រជាកសិករធ្វើការរៀបចំឱ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ (ពិសេសអាហារពេលព្រឹក) សម្រាប់ទទួលភ្ញៀវទេសចរមកធ្វើវិស្សមកាល ឬដំណើរកំសាន្តដែលមកទស្សនាកំសាន្តតំបន់នោះចាប់ពី ០១យប់ ឬអ្នកបំរើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅតាមសហគមន៍ ឬជនបទ។ ផ្ទះស្នាក់ជនបទជាសម្បទាស្នាក់នៅសាមញ្ញមួយបែបដែលបំរើដល់ វិស័យកសិ-ទេសចរណ៍ ដែលកសិករ ឬម្ចាស់កសិដ្ឋានជាអ្នកដើរ តួជាម្ចាស់សេវាកម្មរៀបចំសម្រាប់ទទួលភ្ញៀវទេសចរតែម្តង។ |
| ៣ | ផ្ទះស្នាក់ទីក្រុង | សំដៅដល់ប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅស្ថានប្រជាពលរដ្ឋនៅទីក្រុង ឬតាមទីប្រជុំជន ដែលម្ចាស់ផ្ទះធ្វើការរៀបចំឱ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ (ពិសេសអាហារពេលព្រឹក) សម្រាប់ទទួលភ្ញៀវទេសចរមកធ្វើវិស្សមកាល ឬដំណើរទស្សនាកំសាន្តតំបន់នោះចាប់ពី ០១យប់ ឬអ្នកបំរើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ន នៅទីក្រុង ឬទីប្រជុំជន។ |

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលទេសចរណ៍គុណភាពសេវាកម្មផ្ទះស្នាក់ មានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖

១. ធានាគុណភាពនៃអ្នកផ្តល់សេវាកម្មស្នាក់នៅ

២. ការគ្រប់គ្រងគុណភាពសេវាស្នាក់នៅ

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ "**ប្រសិទ្ធិភាព និងគុណភាព**" ដែលនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយស្មារតីប្រុងប្រយ័ត្ន ដើម្បីសហគមន៍អាចឈានឆ្ពោះទៅរកការពង្រឹងគុណភាពផ្ទះស្នាក់ឱ្យកាន់តែល្អប្រសើរឡើង។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន០២ ដូចខាងក្រោម៖

ដូចនេះ លក្ខខណ្ឌត្រូវសម្រាប់សូចនាករគោលនេះ រួមមានដូចខាងក្រោម៖

**ករណីទី១៖** ជាប្រភេទនៃ "**វិធានការលើកទឹកចិត្តប្រជាសហគមន៍មូលដ្ឋាន**"

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីលទ្ធផលដែលសម្រេចបាននាពេលកន្លងមក

**ករណីទី២៖** ជាប្រភេទនៃ "**វិធានការជម្រុញឱ្យអនុវត្តប្រជាសហគមន៍មូលដ្ឋាន**"

- បង្ហាញពីវត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋាន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យនាំគ្នាចូលរួមក្នុងការពង្រឹងសេវាកម្មផ្ទះស្នាក់ទាំងអស់គ្នា
- បង្ហាញពីវត្តមាននៃអង្គភាពទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់សហគមន៍នោះ

## តារាងបំពេញលក្ខណ្ឌតម្រូវ

| នៃសូចនាករគោលទេសចរណ៍គុណភាពសេវាកម្មផ្ទះស្នាក់ | | | |
|---|---|---|---|
| **ករណីទី១៖ ជាប្រភេទនៃ "វិធានការលើកទឹកចិត្ត"** | | | |
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋាន | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់ | • មានគោលការណ៍ណែនាំក្នុងគោលបំណងដើម្បីលើកទឹកចិត្តទៅដល់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់ |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | លទ្ធផលដែលសម្រេចបាននាពេលកន្លងមក | រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមជាមួយនឹងយន្តគ្រប់គ្រងដែលបានដាក់ចេញ | • មានបញ្ជីឈ្មោះរាយនាម(16) ក្រុមការងារទាំងអស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋាលផ្ទាល់ |
| **ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"** | | | |
| ១ | វត្តមាននៃវិធានការជម្រុញឱ្យមានការអនុវត្តរបស់ | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីជម្រុញឱ្យ | • មានសេចក្តីសម្រេច គោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា<br>• មានសេចក្តីប្រកាសជាផ្លូវការ |

[16] តារាងទី០៣

| | | | |
|---|---|---|---|
| | ប្រជាសហគមន៍មូលដ្ឋាន | មានការអនុវត្តរបស់ប្រជាសហគមន៍មូលដ្ឋានឱ្យមានការចូលរួមទាំងអស់គ្នា | |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្ដីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្ដីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្តជាក់ស្ដែងរបស់សហគមន៍នោះ | ធ្វើការបែកចែកជាក្រុមការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | • មានបញ្ជីឈ្មោះរាយនាម(17)ក្រុមការងារទាំងអស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| | និង | រៀបចំជាតារាងផែនការសកម្មភាព | • តារាងផែនការសកម្មភាព(18)របស់អ្នកទទួលខុសត្រូវលើការងារនេះ |
| | និង | ចងក្រងរបាយការណ៍បូកសរុបការងារប្រចាំខែ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់<br>• រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |

## គ. និតិវិធីក្នុងការផ្ដល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោល គុណភាពសេវាកម្មផ្ទះស្នាក់ សម្រាប់ការផ្ដល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

17

18

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **“កម្រិតមធ្យម”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់”** | លក្ខណៈវិនិច្ឆ័យ **“កម្រិតខ្ពស់បំផុត”** |
|---|---|---|---|---|---|
| ៧. គុណភាពសេវាកម្មផ្ទះស្នាក់ | ២ | ៣៣ | **២០** | **១១** | **២** |



១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា ***(តារាងភស្តុតាងបញ្ជាក់)***



៣. ការប្រមូលរូបភាពសកម្មភាពនានា ***(តារាងភស្តុតាងបញ្ជាក់)***

⚠ **<u>សំគាល់៖</u>** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ។*

## ៨ សូចនាករគោលនៃការអនុវត្តប្រតិបត្តិករទេសចរណ៍សហគមន៍

### កម្មវត្ថុនៃសូចនាករនៃការអនុវត្តប្រតិបត្តិករទេសចរណ៍សហគមន៍

ដើម្បីចូលរួមដល់ចលនាប្រឡងប្រណាំងសហគមន៍ទេសចរណ៍គម្រូ សហគមន៍ទេសចរណ៍គឺត្រូវមានការផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់ទេសចរដែលមកលេងកម្សាន្តនៅក្នុងសហគមន៍ ដោយរួមមានជាសម្បទា ឬសេវាកម្មទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ ដូចនេះ គឺចាំបាច់ក្នុងការជំរុញ និងលើកទឹកចិត្ត ដល់ប្រតិបត្តិករទេសចរណ៍ ឱ្យខិតខំប្រឹងប្រែងផ្តល់សេវា បដិសណ្ឋារកិច្ចល្អប្រកប ដោយស្តង់ដារ ត្រឹមត្រូវ ស្មោះត្រង់ និងកក់ក្តៅដល់ភ្ញៀវទេសចរ គាំទ្រផ្សព្វផ្សាយ យុទ្ធនាការ កម្ពុជាៈ “ព្រះរាជាណាចក្រអច្ឆរិយៈ” ផ្តល់ភាពកក់ក្តៅដល់ភ្ញៀវទេសចរ ។

## ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | ការី ទេសចរណ៍ | សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ច ព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ ផ្សេងៗទៀតសម្រាប់លក់ដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា។ |
| ២ | ការី ទេសចរណ៍ សហគមន៍ | សំដៅលើការីទេសចរណ៍ទាំងឡាយណាដែលទទួលខុសត្រូវ (១)ក្នុងការនាំទេសចរទៅកាន់តំបន់សហគមន៍ទេសចរណ៍ (២)បង្ហាញពីការយកចិត្តចំពោះនិរន្តរភាពធម្មជាតិ និងវប្បធម៌ (៣) គាំទ្រដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៃសហគមន៍មូលដ្ឋានដែលមានចែងក្នុងលក្ខន្តិកៈសហគមន៍ទេសចរណ៍។ |
| ៣ | ភ្នាក់ងារ ទេសចរណ៍ | សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរ ដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត រាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ។ |
| ៤ | អាជ្ញាបណ្ណ មគ្គុទ្ទេសក៏ ទេសចរណ៍ | សំដៅដល់អាជ្ញាបណ្ណមគ្គុទ្ទេសក៏ទេសចរណ៍ ដែលផ្តល់ដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់មគ្គុទ្ទេសក៏ទេសចរណ៍ ជាអាជ្ញាបណ្ណពេញសិទ្ធិ ឬអាជ្ញាបណ្ណបណ្តោះអាសន្ន។ |
| ៥ | អ្នកដឹកនាំ ក្រុម ទេសចរ | សំដៅដល់បុគ្គលដែលការីទេសចរណ៍បានចាត់ឱ្យបំពេញតួនាទី និងភារកិច្ចជាអ្នកនាំក្រុមទេសចរ ក្នុងរយៈពេលនៃការប្រើប្រាស់ខ្សែទស្សនកិច្ចជួយសម្របសម្រួល និងបង្កភាពងាយស្រួលដល់ការអនុវត្ត ការងារនៃមគ្គុទ្ទេសក៏ទេសចរណ៍។ |

| | | |
|---|---|---|
| ៦ | កញ្ចប់ខ្សែទស្សនកិច្ច | សំដៅដល់កញ្ចប់សេវាកម្មទេសចរណ៍រៀបចំឡើង ដោយការីទេសចរណ៍រួមបញ្ចូលនូវសេវាកម្មយ៉ាងតិចពីរ ក្នុងចំណោមសេវាកម្មចាំបាច់ដូចជាសេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ការធ្វើទស្សនកិច្ច សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងសេវាផ្សេងទៀត ដែលពាក់ព័ន្ធដោយមានថ្លៃលក់មួយជាក់លាក់ និងស្ថិតក្នុងថេរវេលាប្រតិបត្តិជាកំណត់។ |

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃការអនុវត្តប្រតិបត្តិករទេសចរណ៍សហគមន៍ មានសូចនាករលំអិតចំនួន ០៥ ដែលរួមមានដូចខាងក្រោមនេះ៖




លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ “**ប្រសិទ្ធិភាពការងារ**” ដែលនេះ ទាមទារឱ្យមានយន្តការគ្រប់គ្រងច្បាស់លាស់មួយ ដើម្បីអាចអនុវត្តប្រតិបត្តិករទេសចរណ៍សហគមន៍មានប្រសិទ្ធភាព។ ដូចនេះ លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន ០៤ ដូចខាងក្រោម៖

- ព័ត៌មានអំពីចំនួនការីទេសចរណ៍សហគមន៍នាពេលបច្ចុប្បន្នដែលមាន

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តឱ្យការីទេសចរណ៍មានទំនាក់ទំនងល្អជាមួយភ្ញៀវ
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់ការីទេសចរណ៍

ខាងក្រោមនេះ ជាតារាងបង្ហាញពីចំនុចគន្លឹះដើម្បីបំពេញលក្ខខណ្ឌតម្រូវទាំង០៤ខាងលើនេះ

| តារាងបំពេញលក្ខណ្ឌតម្រូវ<br>នៃសូចនាករគោលការអនុវត្តនៃប្រតិបត្តិទេសចរណ៍សហគមន៍ | | | |
|---|---|---|---|
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមានព័ត៌មានអំពីចំនួនការីទេសចរណ៍សហគមន៍នាពេលបច្ចុប្បន្ន | ធ្វើបញ្ជីសម្រង់ស្ថិតិអំពីចំនួនការីទេសចរណ៍សហគមន៍ដែលកំពុងបម្រើការងារនៅក្នុងសហគមន៍មូលដ្ឋាន | • តារាងសម្រង់ស្ថិតិដែលបានបញ្ជាក់ ឬចុះហត្ថលេខាពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
| ២ | វត្តមាននៃវិធានការលើកទឹកចិត្តឱ្យការីទេសចរណ៍មានទំនាក់ទំនងល្អជាមួយភ្ញៀវ | រៀបចំជាផែនការ ឬគោលការណ៍លើកទឹកចិត្តចំពោះការចូលរួមរបស់ការីទេសចរណ៍សហគមន៍ | • និតិវិធីនានាដែលបានជម្រុញឱ្យមានការលើកទឹកចិត្តចូលរួមរបស់ការីទេសចរណ៍សហគមន៍មូលដ្ឋាន |
| ៣ | បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ | រៀបចំ និងចាក់ថែងសមាសភាពក្នុងការអនុវត្តន៏ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៤ | បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់ការីទេសចរណ៍ | ធ្វើការបែកចែកជាក្រុមការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | • មានបញ្ជីឈ្មោះរាយនាមក្រុមការងារទាំងអស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |

## គ. និតិវិធីក្នុងការផ្តល់ពិន្ទុ

នៅក្នុងតារាងវាយតម្លៃសម្រាប់សូចនាករគោលនៃការអនុវត្តប្រតិបត្តិករទេសចរណ៍សហគមន៍សម្រាប់ការផ្តល់ពិន្ទុដល់សហគមន៍ទេសចរណ៍គឺដូចមានតារាងខាងក្រោមនេះ៖

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យសរុប | លក្ខណៈវិនិច្ឆ័យ **"កម្រិតមធ្យម"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់"** | លក្ខណៈវិនិច្ឆ័យ **"កម្រិតខ្ពស់បំផុត"** |
|---|---|---|---|---|---|
| ៨. ការអនុវត្តនៃប្រតិបត្តិករទេសចរណ៍សហគមន៍ | **៥** | **៣៤** | **១៦** | **១២** | **៦** |



១. ការចុះត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ការចុះប្រមូលឯកសារពាក់ព័ន្ធនានា (***តារាង**ភស្តុតាងបញ្ជាក់*)



៣. ការប្រមូលរូបភាពសកម្មភាពនានា (***តារាង**ភស្តុតាងបញ្ជាក់*)

⚠ **<u>សំគាល់៖</u>** *ការផ្តល់ពិន្ទុគឺចាំបាច់ត្រូវទាមទារឯកសារពាក់ព័ន្ធនានា រួមទាំងរូបភាពភ្ជាប់មកជាមួយផងដែរ ក្នុងករណីមិនមានឯកសារគ្រប់គ្រាន់។ ក្រុមការងារស្នើសុំឱ្យមានការបំពេញបន្ថែមទៀតនាពេលក្រោយ។ ប្រសិនបើមិនប្រគល់ឱ្យឯកសារយោងនឹងមិនត្រូវទទួលបានពិន្ទុឡើយ*

## ផ្នែកទី២៖ យន្តការនៃការផ្តល់ពិន្ទុជូនសហគមន៍ទេសចរណ៍

តារាងវាយតម្លៃស្តង់ដាសហគមន៍ទេសចរណ៍បានធ្វើការកំណត់ផ្តល់ពិន្ទុដល់សហគមន៍ ដែលមានពិន្ទុសរុបរួមទាំងអស់ចំនួន ១៦៩ លក្ខណៈវិនិច្ឆ័យ ស្មើនឹង១៦៩ពិន្ទុផងដែរ។ នៅក្នុងនោះ ការផ្តល់ពិន្ទុលើលក្ខណៈវិនិច្ឆ័យមាន០៣កម្រិតផ្សេងៗគ្នា ដែលរួមមានដូចខាងក្រោមនេះ៖




**ការទទួលឡាបិល៖** ស្តង់ដាសហគមន៍ទេសចរណ៍នឹងផ្តល់ជូនសហគមន៍ទេសចរណ៍ណាដែលទទួលបានពិន្ទុស្មើនឹង **៦០% នៃលក្ខណៈវិនិច្ឆ័យកម្រិតមធ្យម កម្រិតខ្ពស់ និងកម្រិតខ្ពស់បំផុត**។ *(ចូលមើលសេចក្តីពន្យល់បន្ថែមទី១)*

**ឡាបិល៖** ស្តង់ដាសហគមន៍ទេសចរណ៍មានសុពលភាពរយៈពេល**០២ឆ្នាំ**។

**វិញ្ញាបនប័ត្រ៖** បញ្ជាក់ពីការទទួលស្គាល់សហគមន៍ទេសចរណ៍ នឹងផ្តល់ជូនសហគមន៍ទេសចរណ៍ណាដែលទទួលបានពិន្ទុស្មើនឹង៥០%យ៉ាងតិច នៃលក្ខណៈវិនិច្ឆ័យមធ្យម។ *(ចូលមើលសេចក្តីពន្យល់បន្ថែមទី២)*

**សេចក្តីពន្យល់បន្ថែមទី១៖ ការទទួលបានឡាបិល**

១. ដើម្បីទទួលបានឡាបិលកម្រិតមធ្យមមានផ្ការំដួង១ទង គឺចាំបាច់ត្រូវទទួលបានពិន្ទុយ៉ាងហោចណាស់ប្រមាណជា **៥២ពិន្ទុ** ដែលស្មើនឹង៦០%នៃលក្ខណៈវិនិច្ឆ័យកម្រិតមធ្យម

២. ដើម្បីទទួលបានឡាបិលកម្រិតខ្ពស់មានផ្ការំដួង២ទង គឺចាំបាច់ត្រូវទទួលបានពិន្ទុយ៉ាងហោចណាស់ប្រមាណជា **៨៤ពិន្ទុ** ដោយក្នុងនោះគឺចាំបាច់ត្រូវមាន៖ **៥២ពិន្ទុនៃលក្ខណៈវិនិច្ឆ័យកម្រិតមធ្យម និង៣២ពិន្ទុ ដែលស្មើនឹង៦០%នៃលក្ខណៈវិនិច្ឆ័យកម្រិតខ្ពស់**

៣. ដើម្បីទទួលបានឡាបិលកម្រិតខ្ពស់បំផុតមានផ្ការំដួង៣ទង គឺចាំបាច់ត្រូវទទួលបានពិន្ទុយ៉ាងហោចណាស់ប្រមាណជា **១០៣ពិន្ទុ** ដោយក្នុងនោះគឺចាំបាច់ត្រូវមាន៖ **៥២ពិន្ទុនៃលក្ខណៈវិនិច្ឆ័យកម្រិតមធ្យម ៣២ពិន្ទុនៃលក្ខណៈវិនិច្ឆ័យកម្រិតខ្ពស់ និង១៩ពិន្ទុ ដែលស្មើនឹង៦០%នៃលក្ខណៈវិនិច្ឆ័យកម្រិតខ្ពស់បំផុត**

**ឡាបិលមាន០៣កម្រិត៖** ឡាបិលកម្រិតមធ្យមមានផ្ការំដួល១ទង ឡាបិលកម្រិតខ្ពស់មានផ្ការំដួល២ទង និងឡាបិលកម្រិតខ្ពស់បំផុតមានផ្ការំដួល៣ទង។




## សេចក្តីពន្យល់បន្ថែមទី២៖ ការទទួលបានវិញ្ញាបនប័ត្រ

ក្នុងករណីក្រុមការងារចុះវាយតម្លៃលើទិដ្ឋភាពជាក់ស្តែងរបស់សហគម៍ទេសចរណ៍ដោយផ្ទាល់ និងឯកសារពាក់ព័ន្ធនានា នូវមានកម្រិតនូវឡើយ។ ដើម្បីចូលរួមលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានដែលបានខិតខំប្រឹងប្រែងអភិវឌ្ឍសហគមន៍ទេសចរណ៍របស់ខ្លួនផ្ទាល់នោះ។ ក្រុមការងារចុះវាយតម្លៃនឹងពិនិត្យទៅលើលទ្ធភាពរបស់សហគមន៍នោះ ដើម្បីអាចនឹងទទួលបានជាវិញ្ញាបនប័ត្រវិញ ក្នុងករណីដែលសហគមន៍ទេសចរណ៍នោះអាចមានលទ្ធភាពទទួលបាន **៤៣ ពិន្ទុ ស្មើនឹង៥០%យ៉ាងតិចនៃលក្ខណះវិនិច្ឆ័យមធ្យម**។




## ផ្នែកទី៣៖ ដំណើរការនៃការវាយតម្លៃសហគមន៍ទេសចរណ៍

ការប្រើប្រាស់សៀវភៅស្តង់ដាសហគមន៍ទេសចរណ៍ គឺជាមូលដ្ឋានគ្រឹះមួយដ៏សំខាន់មួយទុកសម្រាប់ធ្វើការវាស់វែងអំពីកម្រិតចំណាត់ថ្នាក់របស់សហគមន៍ទេសចរណ៍ ថាតើសហគមន៍ទេសចរណ៍ទាំងអស់នោះបានបំពេញលក្ខណ្ឌនៃស្តង់ដាសហគមន៍ទេសចរណ៍បានត្រឹមកម្រិតណាដែរ។ ក៏ប៉ុន្តែទន្ទឹមនេះផងដែរ ក្រុមការងារចុះវាយតម្លៃសហគមន៍ទេសចរណ៍ចាំបាច់ត្រូវតែឆ្លងកាត់សិក្ខាសាលាផ្សព្វផ្សាយស្តីពី “**គោលការណ៍ណែនាំក្នុងការចុះវាយតម្លៃស្តង់ដាសហគមន៍ទេសចរណ៍**” ដោយមានការរៀបចំដោយនាយកដ្ឋានអភិវឌ្ឍផលិតផលទេសចរណ៍ ដែលជានាយកដ្ឋានជំនាញទទួលបន្ទុកក្នុងការវាយតម្លៃសហគមន៍ទេសចរណ៍។

សិក្ខាសាលានេះ មានគោលបំណងដើម្បីផ្សព្វផ្សាយពី៖

១. ទិដ្ឋភាពទូទៅនៃការចលនាប្រឡងប្រណាំងសហគមន៍ទេសចរណ៍គម្រូ

២. កម្មវត្ថុនៃការចលនាប្រឡងប្រណាំងសហគមន៍ទេសចរណ៍គម្រូ

៣. បង្ហាញពីវិធីសាស្ត្រក្នុងការចុះវាយតម្លៃសហគមន៍ទេសចរណ៍គម្រូ

៤. ការចែករំលែងបទពិសោធន៍ការចុះវាយតម្លៃសហគមន៍ទេសចរណ៍គម្រូ

## ផ្នែកទី៤៖ ដំណើរការនៃការប្រឡងប្រណាំងសហគមន៍ទេសចរណ៍



# ឧបសម្ព័ន្ធ

# តារាងទី០១

## គំរូតារាងក្រុមការងារទទួលបន្ទុកការងារក្នុងសហគមន៍មូលដ្ឋានផ្ទាល់

ពត៌មានរបស់សហគមន៍ទេសចរណ៍.....................................................

| តារាងក្រុមការងារទទួលបន្ទុកការងារក្នុងសហគមន៍មូលដ្ឋានផ្ទាល់សម្រាប់ឆ្នាំ២០២..... | | | |
|---|---|---|---|
| **ល.រ** | **ឈ្មោះ** | **តួនាទី** | **ភារៈកិច្ច** |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |

ធ្វើនៅ......................ថ្ងៃទី.........ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

# តារាងទី០២

## គំរូតារាងក្រុមការងារពាក់ព័ន្ធដែលបានចូលរួមការងារក្នុងសហគមន៍ទេសចរណ៍

## សម្រាប់ពិធានការលើកទឹកចិត្ត "សុខមាលភាពសង្គម"

**ករណីទី១៖ ជាប្រភេទនៃ "ពិធានការលើកទឹកចិត្ត"**

| តារាងក្រុមការងារពាក់ព័ន្ធដែលបានចូលរួមការងារក្នុងសហគមន៍ទេសចរណ៍សម្រាប់ឆ្នាំ២០២....... សម្រាប់ពិធានការលើកទឹកចិត្ត "សុខមាលភាពសង្គម" | | | | |
|---|---|---|---|---|
| ល.រ | ឈ្មោះ | ស្ថាប័នពាក់ព័ន្ធចូលរួម | វិធីសាស្ត្រការអនុវត្ត | លទ្ធផលទទួលបាន |
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |

ធ្វើនៅ....................ថ្ងៃទី.........ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

**ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"**

| តារាងក្រុមការងារពាក់ព័ន្ធដែលបានចូលរួមការងារក្នុងសហគមន៍ទេសចរណ៍សម្រាប់ឆ្នាំ២០២.......<br>សម្រាប់វិធានការជម្រុញឱ្យអនុវត្ត "សុខមាលភាពសង្គម" | | | | |
|---|---|---|---|---|
| **ល.រ** | **ឈ្មោះ** | **ស្ថាប័នពាក់ព័ន្ធចូលរួម** | **វិធីសាស្ត្រការជម្រុញឱ្យអនុវត្ត** | **លទ្ធផលទទួលបាន** |
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |

ធ្វើនៅ.....................ថ្ងៃទី.........ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

## តារាងទី០៣

## គំរូតារាងផែនការសកម្មភាពរបស់អ្នកទទួលខុសត្រូវ

ពត៌មានរបស់សហគមន៍ទេសចរណ៍......................................................

| តារាងផែនការសកម្មភាពរបស់អ្នកទទួលខុសត្រូវ សម្រាប់ឆ្នាំ២០២...... | | | | | |
|---|---|---|---|---|---|
| ល.រ | ឈ្មោះគម្រោង | ស្ថាប័នពាក់ព័ន្ធចូលរួម | ទីតាំងអនុវត្តគម្រោង | កាលបរិច្ឆេទ | អ្នកទទួលបន្ទុកការងារ |
| ១. | | | | | |
| ២. | | | | | |
| ៣. | | | | | |
| ៤. | | | | | |

ធ្វើនៅ.....................ថ្ងៃទី.........ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

# តារាងទី០៤

## គំរូតារាងសម្រង់ស្ថិតិគម្រោងស្ថិតក្នុងផែនការអនុវត្ត "វិធានការជម្រុញឱ្យអនុវត្ត"

## សម្រាប់វិធានការលើកទឹកចិត្ត "សុខមាលភាពសង្គម"

**ករណីទី៣៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"**

| តារាងសម្រង់ស្ថិតិគម្រោងស្ថិតក្នុងផែនការអនុវត្ត "វិធានការជម្រុញឱ្យអនុវត្ត" សម្រាប់ឆ្នាំ២០២...... | | | | | | |
|---|---|---|---|---|---|---|
| ល.រ | ឈ្មោះគម្រោង | ស្ថាប័នពាក់ព័ន្ធចូលរួម | ទីតាំងអនុវត្តគម្រោង | លទ្ធផលទទួលបាន | កាលបរិច្ឆេទ | អ្នកទទួលបន្ទុកការងារ |
| ១. | | | | | | |
| ២. | | | | | | |
| ៣. | | | | | | |
| ៤. | | | | | | |

ធ្វើនៅ.....................ថ្ងៃទី......... ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

## តារាងទី០៥

## គំរូតារាងសម្រង់ស្ថិតិទីតាំងដែលមានការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ

ពត៌មានរបស់សហគមន៍ទេសចរណ៍.....................................................

| តារាងសម្រង់ស្ថិតិទីតាំងដែលមានការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ សម្រាប់ឆ្នាំ២០២...... | | | | | |
|---|---|---|---|---|---|
| ល.រ | ឈ្មោះទីតាំង | ទំហំទីតាំង (ម២) | ប្រភេទការគ្រប់គ្រង និងអភិរក្សធនធាន | លទ្ធផលទទួលបាន | អ្នកទទួលបន្ទុកការងារ |
| ១. | | | | | |
| ២. | | | | | |
| ៣. | | | | | |
| ៤. | | | | | |

ធ្វើនៅ...................... ថ្ងៃទី......... ខែ.........ឆ្នាំ២០២..................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

## តារាងទី០៦

## គំរូតារាងសម្រង់ស្ថិតិស្ដីពីចំនួនប្រជាសហគមន៍មូលដ្ឋាននាពេលបច្ចុប្បន្ន

ពត៌មានរបស់សហគមន៍ទេសចរណ៍......................................................

| **តារាងសម្រង់ស្ថិតិស្ដីពីចំនួនប្រជាសហគមន៍ក្នុងមូលដ្ឋាន សម្រាប់ឆ្នាំ២០២.....** | | | | | | |
|---|---|---|---|---|---|---|
| **ល.រ** | **ពត៌មានទូទៅ** | | | **ការចូលរួមលើកទឹកចិត្ត** | | **អ្នកទទួលបន្ទុកការងារ** |
| | **ចំនួនគ្រួសារ** | **ចំនួនសមាជិកគ្រួសារ** | **មុខរបរ** | **វិធីសាស្រ្តអនុវត្ត** | **លទ្ធផលទទួលបាន** | |
| ១. | | | | | | |
| ២. | | | | | | |
| ៣. | | | | | | |
| ៤. | | | | | | |

ធ្វើនៅ...................... ថ្ងៃទី......... ខែ.........ឆ្នាំ២០២...................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

## តារាងទី០៧

## គំរូតារាងផែនការសកម្មភាពស្តីពីសកម្មភាពទំនាក់ទំនងរវាងប្រជាសហគមន៍មូលដ្ឋាន និងភ្ញៀវទេសចរ

ពត៌មានរបស់សហគមន៍ទេសចរណ៍.......................................................

| **តារាងផែនការសកម្មភាពស្តីពីសកម្មភាពទំនាក់ទំនងរវាងប្រជាសហគមន៍មូលដ្ឋាន និងភ្ញៀវទេសចរ សម្រាប់ឆ្នាំ២០២......** | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ឈ្មោះសកម្មភាព** | **ស្ថាប័នពាក់ព័ន្ធចូលរួម** | **ទីតាំងអនុវត្តសកម្មភាព** | **កាលបរិច្ឆេទ** | **អ្នកទទួលបន្ទុកការងារ** |
| ១. | | | | | |
| ២. | | | | | |
| ៣. | | | | | |
| ៤. | | | | | |

ធ្វើនៅ.......................ថ្ងៃទី.......... ខែ..........ឆ្នាំ២០២...................

**បានឃើញ និងឯកភាព**

**ប្រធានសហគមន៍ទេសចរណ៍**

*(ហត្ថលេខា)*

**ឈ្មោះប្រធានសហគមន៍**

# ២. ផ្ទះស្នាក់កម្ពុជា

## ផ្នែកទី១៖ ផ្ទះស្នាក់កម្ពុជា

ផ្ទះស្នាក់ត្រូវបានគេចាត់ទុកថាជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍទេសចរណ៍សហគមន៍ ក៏ដូចជាការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍តាមរយៈការបង្កើតឱកាសការងារ ការបង្កើនប្រាក់ចំណូលប្រចាំថ្ងៃដោយផ្ទាល់ ជាពិសេសគឺការចូលរួមក្នុងការថែរក្សាសម្បត្តិវប្បធម៌

ជាតិ តាមរយៈ ការរៀបចំផ្ទះស្នាក់សហគមន៍មានទំរង់រចនាបទប្រពៃណីខ្មែរ។ ជាមួយគ្នានេះក្នុងវេទិកាទេសចរណ៍អាស៊ានលើកទី៣៨ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-១៨ ខែមករា ឆ្នាំ២០១៩ នៅទីក្រុងហាឡុង ប្រទេសវៀតណាម អាស៊ានបានទទួលស្គាល់ផ្ទះស្នាក់កម្ពុជាចំនួន៥ ដែលមានគុណភាពសេវាកម្មស្របតាមស្តង់ដា ដែលបានដាក់ចុះឱ្យអនុវត្តដោយសមាគមអាស៊ាន។

នៅក្នុងនោះ ស្តង់ដាផ្ទះស្នាក់ត្រូវបានចែកចេញជា០៣ ដែលរួមមាន៖

ក. ស្តង់ដាផ្ទះស្នាក់សហគមន៍ ( Community Homestay)

ខ. ស្តង់ដាផ្ទះស្នាក់ជនបទ (Rural Homestay)

គ. ស្តង់ដាផ្ទះស្នាក់ទីក្រុង (Urban Homestay)

ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ និងអនុវត្តគោលការណ៍ណែនាំនេះ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ក្រុមការងារបានរៀបចំបែងចែកជា ០៤ចំនុចបន្ថែមទៀតដែលរួមមានដូចខាងក្រោម៖

- និយមន័យនៃពាក្យគន្លឹះក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- លក្ខខណ្ឌតម្រូវនៅក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- និតិវិធីក្នុងការផ្តល់ពិន្ទុសម្រាប់ការវាយតម្លៃ
- រូបភាពបញ្ជាក់បន្ថែម (ក្នុងករណីចាំបាច់)

# ក. ផ្ទះស្នាក់

# សហគមន៍

**<u>និយមន័យ៖</u>** គឺជាទីកន្លែងដែលភ្ញៀវទេសចរអាចស្នាក់នៅជាមួយសមាជិកគ្រួសារម្ចាស់ផ្ទះ និងទទួលបានបទពិសោធន៍ពីការរស់នៅប្រចាំថ្ងៃនៃគ្រួសារម្ចាស់ផ្ទះ និងសហគមន៍ដោយផ្ទាល់ ឬដោយប្រយោល។ ស្តង់ដានេះ រួមមានសូចនាករគោលចំនួន**០៩ មានសូចនាករលំអិតចំនួន ២៨** និងមាន**លក្ខណៈវិនិច្ឆ័យសរុបចំនួន៩៣**។

## ១ សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់សហគមន៍

**កម្មវត្ថុនៃសូចនាករនៃម្ចាស់ផ្ទះស្នាក់សហគមន៍**

នៅក្នុងសូចនាករនៃម្ចាស់ផ្ទះស្នាក់សហគមន៍ គឺរៀបចំឡើងដោយផ្តោតសំខាន់ទៅលើសូចនាករល្អិតចំនួន០២ ដែលរួមមានចំនួន០៦ លក្ខណៈវិនិច្ឆ័យ និង**០៤លក្ខណៈវិនិច្ឆ័យចាំបាច់** ក្នុងគោលបំណងដើម្បីពង្រឹងគុណភាព និងសមត្ថភាពដល់ម្ចាស់ផ្ទះស្នាក់សហគមន៍ឱ្យទទួលបានចំណេះដឹងសមស្របតាមស្តង់ដាផ្ទះស្នាក់កម្ពុជា ជាពិសេសគឺការទទួលស្គាល់គុណភាពសេវាកម្មផ្ទះស្នាក់សហគមន៍។

## ក. និយមន័យនៃពាក្យគន្លឹះ

| ល.រ | ពាក្យគន្លឹះ | សេចក្តីពន្យល់នៃពាក្យគន្លឹះ |
|---|---|---|
| ១ | មជ្ឈមណ្ឌលសហគមន៍ | សំដៅដល់កន្លែងសម្រាប់សកម្មភាពសហគមន៍ដូចជា ការស្វាគមន៍ពេលភ្ញៀវអញ្ជើញមកដល់ ការសំដែងសិល្បៈ ការដាក់តាំងបង្ហាញវត្ថុសិល្បៈ ឬសកម្មភាពសង្គមនានា។ |
| ២ | ក្រមសីលធម៌វិជ្ជាជីវៈ | សំដៅដល់ច្បាប់ទូទ្មានដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗ នៃឧស្សាហកម្មទេសចរណ៍មានចរិតលក្ខណៈជាអភិសមាចារ ដោយភ្ជាប់ជាមួយនូវការអប់រំ តម្រែតម្រង់ និងពន្យល់ណែនាំប្រតិបត្តិករទេសចរណ៍ ក្នុងគោលបំណងលើកម្ពស់ចរិយាមារយាទល្អប្រពៃការគោរពអនុវត្តសីលធម៌វិជ្ជាជីវៈ។ |
| ៣ | ការបណ្តុះបណ្តាលពីសហគមន៍មួយទៅសហគមន៍មួយទៀត | កម្មវិធីបណ្តុះបណ្តាលត្រូវរៀបចំឡើងដោយការធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់ផ្លាស់ប្តូរបទពិសោធន៍ពីសហគមន៍ផ្ទះស្នាក់ ដែលទទួលបានជោគជ័យ និងបង្កើតឲ្យមានទំនាក់ទំនងដើម្បីអភិវឌ្ឍន៍ផ្ទះស្នាក់។ |
| ៤ | ការទទួលស្គាល់គុណភាព | សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងទេសចរណ៍ ឬដែលចេញដោយសមាគមឧស្សាហកម្មទេសចរណ៍ ដើម្បីបញ្ជាក់ទទួលស្គាល់គុណភាពផលិតផល ឬសេវាកម្មទេសចរណ៍ដែលបានឆ្លើយតបទៅនឹងស្តង់ដាធានាគុណភាព កំណត់ដោយក្រសួងទេសចរណ៍។ |

## ខ. លក្ខខណ្ឌតម្រូវ

នៅក្នុងសូចនាករគោលនៃម្ចាស់ផ្ទះស្នាក់សហគមន៍ មានសូចនាករលំអិតចំនួន០២ ដែលរួមមានដូចខាងក្រោមនេះ៖

**១. អ្នកភូមិ និងសហគមន៍**

**២. អ្នកផ្តល់សេវាកម្មផ្ទះស្នាក់**

លក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ គឺជាកម្មវត្ថុចំបងមួយក្នុងការវាយតម្លៃនោះគឺ "**ប្រសិទ្ធិភាព និងគុណភាព**" ដែលនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ប្រកបដោយស្មារតីប្រុងប្រយ័ត្ន ដើម្បីម្ចាស់ផ្ទះស្នាក់សហគមន៍អាចឈានឆ្ពោះទៅរកការរៀបចំប្រកបដោយស្តង់ដាបាន។ ដូចនេះលក្ខខណ្ឌតម្រូវសម្រាប់សូចនាករគោលនេះ រួមមានចំនួន០២ ដូចខាងក្រោម៖

**<u>ករណីទី១៖</u>** ជាប្រភេទនៃ "**វិធានការលើកទឹកចិត្តដល់ម្ចាស់ផ្ទះស្នាក់សហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ម្ចាស់ផ្ទះស្នាក់សហគមន៍ទាំងអស់ឱ្យនាំគ្នាចូលរួមពង្រឹងប្រសិទ្ធិភាព និងគុណភាពផ្ទះស្នាក់
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីលទ្ធផលដែលសម្រេចបាននាពេលកន្លងមក

**<u>ករណីទី២៖</u>** ជាប្រភេទនៃ "**វិធានការជម្រុញឱ្យអនុវត្តដល់ម្ចាស់ផ្ទះស្នាក់សហគមន៍**"

- បង្ហាញពីវត្តមាននៃវិធានការជម្រុញឱ្យមានការចូលរួមអនុវត្តរបស់ម្ចាស់ផ្ទះស្នាក់ទាំងអស់
- បង្ហាញពីវត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៏វិធានការទាំងអស់នេះ
- បង្ហាញពីសកម្មភាពអនុវត្តជាក់ស្តែងរបស់ម្ចាស់ផ្ទះស្នាក់

| **តារាងបំពេញលក្ខណ្ឌតម្រូវ នៃសូចនាករគោលម្ចាស់ផ្ទះស្នាក់សហគមន៍** | | | |
|---|---|---|---|
| **ករណីទី១៖ ជាប្រភេទនៃ "វិធានការលើកទឹកចិត្ត"** | | | |
| ល.រ | លក្ខខណ្ឌ | ការបំពេញលក្ខខណ្ឌ | ភស្តុតាងបញ្ជាក់ |
| ១ | វត្តមាននៃវិធានការលើកទឹកចិត្តទៅដល់ម្ចាស់ផ្ទះ | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីលើកទឹក | • មានគោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា ក្នុងគោលបំណងដើម្បីលើកទឹកចិត្តទៅដល់ម្ចាស់ផ្ទះស្នាក់ឱ្យមានការចូលរួមទាំង |

| | | | |
|---|---|---|---|
| | ស្នាក់ | ចិត្តទៅដល់ម្ចាស់ផ្ទះស្នាក់ឱ្យមានការចូលរួមទាំងអស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់ | អស់គ្នាក្នុងការពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់ |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | លទ្ធផលដែលសម្រេចបាននាពេលកន្លងមក | រៀបចំជាសម្រង់ស្ថិតិគ្រប់ភាគីពាក់ព័ន្ធដែលបានចូលរួមជាមួយនឹងយន្តគ្រប់គ្រងដែលបានដាក់ចេញ | • របាយការណ៍បូកសរុបការងារដែលមានហត្ថលេខា និងការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ ឬសមាគមន៍ផ្ទះស្នាក់<br>• រូបថត រូបភាព ខ្សែវីដេអូ ឬឯកសារពាក់ព័ន្ធផ្សេងៗដែលបញ្ជាក់ពីសកម្មភាពការងារ |
| **ករណីទី២៖ ជាប្រភេទនៃ "វិធានការជម្រុញឱ្យអនុវត្ត"** | | | |
| ១ | វត្តមាននៃវិធានការជម្រុញឱ្យមានការចូលរួមអនុវត្តរបស់ម្ចាស់ផ្ទះស្នាក់ | រៀបចំចងក្រងជាយន្តការ វិធានការ ឬនីតិវិធីផ្សេងៗ ដើម្បីជម្រុញឱ្យមានការចូលរួមអនុវត្តរបស់ម្ចាស់ផ្ទះស្នាក់ទាំងអស់គ្នា | • មានសេចក្តីសម្រេច គោលការណ៍ណែនាំ ឬលិខិតបទដ្ឋាននានា<br>• មានសេចក្តីប្រកាសជាផ្លូវការចេញដោយប្រធានសហគមន៍មូលដ្ឋាន ឬសមាគមន៍ផ្ទះស្នាក់ |
| ២ | វត្តមាននៃក្រុមការងារទទួលខុសត្រូវក្នុងការអនុវត្តន៍វិធានការទាំងអស់នេះ | រៀបចំ និងចាក់ចែងសមាសភាពក្នុងការអនុវត្តន៍ការងារទាំងអស់នេះ | • សេចក្តីសម្រេច ឬលិខិតបទដ្ឋាននានាដែលមានតម្លៃស្មើស្តីពីការចាត់តាំងតួនាទីភារៈកិច្ចក្នុងការបំពេញការងារនេះ |
| ៣ | សកម្មភាពអនុវត្ត | ធ្វើការបែកចែកជាក្រុម | • មានបញ្ជីឈ្មោះរាយនាមក្រុមការងារទាំង |

| | | | |
|---|---|---|---|
| | ជាក់ស្តែងរបស់ម្ចាស់ផ្ទះស្នាក់ | ការងារតូចៗ សម្រាប់ចុះត្រួតពិនិត្យ | អស់នោះ ដែលមានការបញ្ជាក់ពីប្រធានសហគមន៍មូលដ្ឋានផ្ទាល់ |
